មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights



# ស្ត្រីក្នុងជម្លោះដីធ្លីនៅកម្ពុជា

ខែកញ្ញា ឆ្នាំ ២០១៦

ឧបត្ថម្ភគាំទ្រដោយសប្បុរសពី

diakonia
PEOPLE CHANGING THE WORLD

Sida

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (″ម.ស.ម.ក″) គឺជាអង្គការមិនមែនរដ្ឋាភិបាល (″អង្គការ″) មិនចូលបក្សសម្ពន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ទស្សនៈវិស័យរបស់ ម.ស.ម.ក គឺចង់ឱ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សាដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពនិងត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីចូលរួមក្នុងលិទ្ធិប្រជាធិបតេយ្យនិងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ យើងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាពស្ថាប័នរឹងមាំ ជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែប នៃសង្គមត្រូវបានទទួលយក និងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឱ្យឃើញរូបសត្វព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

របាយការណ៍ស្តីពី *″ស្ត្រីក្នុងជម្លោះដីធ្លីនៅកម្ពុជា″* (″របាយការណ៍″) នេះគឺជាលទ្ធផលកើតចេញពីគម្រោងកម្មវិធីកំណែទម្រង់ដីធ្លីនៃ ម.ស.ម.ក (″គម្រោង″)។ របាយការណ៍នេះពិនិត្យតែទៅលើករណីដែលស្ត្រីនៅប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ដោយសារជម្លោះដីធ្លីតាមរបៀបផ្សេងគ្នាជាច្រើនដោយសារតែលទ្ធភាពរបស់ស្ត្រីក្នុងការបំពេញតួនាទីរបស់ខ្លួន ដែលមានតាមវប្បធម៌ទំនៀមទម្លាប់ខ្មែរ គឺពឹងផ្អែកទាំងស្រុងទៅលើសុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់ពួកគាត់។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះរៀបរៀងឡើងដោយមានការគាំទ្រដោយសប្បុរសពីសហភាពអឺរ៉ុប អង្គការ Diakonia និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍស៊ុយអែត (Sida)។ ខ្លឹមសារនៅក្នុងរបាយការណ៍នេះជាការទទួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬ អង្គការ Diakonia ឬ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍស៊ុយអែត (Sida)នោះទេ។ ម.ស.ម.ក សូមថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ដែលបានចូលរួមក្នុងការស្ទង់មតិ កិច្ចសម្ភាសន៍ និងក្រុមពិភាក្សា ដែលបង្កើតបានជាមូលដ្ឋាននៃការស្រាវជ្រាវនេះ និងជាពិសេសសូមថ្លែងអំណរគុណដល់សមាជិកសហគមន៍ដែលបានឯកភាពឱ្យផ្តិតយករូបភាពសម្រាប់ដាក់លើគម្របរបាយការណ៍នេះ។

# សំណួរ និងមតិឆ្លើយតប

របាយការណ៍នេះ និងឯកសារបោះពុម្ពផ្សេងទៀតទាំងអស់របស់ ម.ស.ម.ក អាចរកមើលបាននៅលើគេហទំព័រ www.cchrcambodia.org និងនៅលើគេហទំព័រដែលទទួលបានពានរង្វាន់ខាងផ្នែកសិទ្ធិមនុស្ស តាមរយៈ www.sithi.org ដែលគ្រប់គ្រងដោយ ម.ស.ម.ក ផ្ទាល់។

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់មតិឆ្លើយតប សូមផ្ញើសារអេឡិចត្រូនិចមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ។ ជម្រើសមួយទៀត លោកអ្នកអាចទាក់ទងផ្ទាល់មកកាន់ ម.ស.ម.ក តាមអាសយដ្ឋាន៖


ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក

ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ៖ +855(0) 23 72 69 01

ទូរសារលេខ៖ +855(0) 23 72 69 02

គេហទំព័រ៖ www.cchrcambodia.org



cc BY NC SA

# មាតិកា

ទំព័រ


និយមន័យ និងពាក្យកាត់ ..... v
ខ្លឹមសារសង្ខេប ..... ១
១. សេចក្តីផ្តើម ..... ៣
១.១ ទិដ្ឋភាពទូទៅពីស្ថានភាពដីធ្លីនៅកម្ពុជា ..... ៣
១.២ ស្ត្រី និងសុវត្ថិភាពកាន់កាប់ដីធ្លី ..... ៤
២. ក្របខណ្ឌគិតយុត្តិ ..... ៦
២.១ ការការពារសិទ្ធិលើដីធ្លីរបស់ស្ត្រី ..... ៦
២.១.១ ការការពារក្រោមច្បាប់អន្តរជាតិ ..... ៦
២.១.២ ការការពារក្រោមច្បាប់ជាតិ ..... ៨
២.២ ការការពារប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ..... ៨
២.២.១ ការការពារក្រោមច្បាប់អន្តរជាតិ ..... ៨
២.២.២ ការការពារក្រោមច្បាប់ជាតិ ..... ៩
៣. គោលបំណង និងវិធីសាស្ត្រ ..... ១២
៣.១ គោលបំណង ..... ១២
៣.២ វិធីសាស្ត្រ ..... ១២
៣.៣ វិសាលភាព និងដែនកំណត់ ..... ១៥
៤. ឥទ្ធិពលនៃវិវាទទៅលើស្ត្រី ..... ១៦
៤.១ ការរំលោភបំពានសិទ្ធិលើដីធ្លី ..... ១៦
៤.១.១ អសន្តិសុខនៃការកាន់កាប់ដីធ្លី ..... ១៦
៤.១.២ ការបណ្តេញចេញដោយបង្ខំ ..... ១៧
៤.១.៣ តំបន់តាំងលំនៅថ្មីមិនគ្រប់គ្រាន់ ..... ១៨
៤.២ ការឃាឃី និងការគំរាមកំហែងពីសំណាក់អាជ្ញាធរ និងស្ថាប័នឯកជន ..... ១៩
៤.៣ អសុវត្ថិភាពផ្នែកសេដ្ឋកិច្ច ..... ១៩
៤.៤ ផលប៉ះពាល់លើទំនាក់ទំនងគ្រួសារ ..... ២០
៤.៥ អំពើហិង្សាក្នុងគ្រួសារ ..... ២១
៤.៦ ផលប៉ះពាល់លើកុមារ ..... ២៣

៤.៧ ផលប៉ះពាល់ផ្នែកចិត្តសាស្ត្រ ............................................................................................២៤
៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..........................................................................................២៦
៥.១ អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា.............................................................................. ២៧
៥.១.១ បញ្ហាអំពើហិង្សាក្នុងគ្រួសារ .............................................................................................. ២៧
៥.១.២ បញ្ហាសុខភាពផ្លូវចិត្ត.......................................................................................................... ២៧
៥.១.៣ បញ្ហាកុមារ...................................................................................................................... ២៧
៥.២ អនុសាសន៍សម្រាប់រដ្ឋសភា ...............................................................................................២៨
៥.៣ អនុសាសន៍សម្រាប់ក្រុមហ៊ុន .............................................................................................២៨
៥.៤ អនុសាសន៍សម្រាប់ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល.........................................................២៨
ឯកសារយោង...........................................................................................................................៣០

# និយមន័យ និងពាក្យកាត់

| | |
|---|---|
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ស៊ីដ័រ | អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| ក្រមរដ្ឋប្បវេណី | ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ (បានធ្វើវិសោធនកម្ម) |
| សង្គមស៊ីវិល | អង្គការសង្គមស៊ីវិល |
| ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ | ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ |
| ការវាយតម្លៃផលប៉ះពាល់បរិស្ថាន | ការវាយតម្លៃប៉ះពាល់បរិស្ថាន |
| សម្បទានដីសេដ្ឋកិច្ច | សម្បទានដីសេដ្ឋកិច្ច |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.អ.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| អង្គការអាយឡូ | អង្គការពលកម្មអន្តរជាតិ |
| ច្បាប់ភូមិបាល | ច្បាប់ភូមិបាលឆ្នាំ២០០១ |
| អង្គការលីកាដូ | សម្ព័ន្ធខ្មែរជំរឿន និងការការពារសិទ្ធិមនុស្ស លីកាដូ |
| គម្រោង | គម្រោងកម្មវិធីកំណែទម្រង់ដីធ្លីនៃ ម.ស.ម.ក |
| អង្គការមិនមែនរដ្ឋាភិបាល | អង្គការមិនមែនរដ្ឋាភិបាល |
| របាយការណ៍ | របាយការណ៍នេះសំដៅលើ "ស្ត្រីក្នុងជម្លោះដីធ្លីនៅកម្ពុជា" |

| | |
|---|---|
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| អង្គការមិនមែនរដ្ឋាភិបាល | អង្គការមិនមែនរដ្ឋាភិបាល |
| គម្រោង | គម្រោងកម្មវិធីកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក |
| របាយការណ៍ | របាយការណ៍នេះសំដៅលើ *"ស្ត្រីក្នុងជម្លោះដីធ្លីនៅកម្ពុជា"* |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| ស.ប.ស.ស | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| គោលការណ៍ណែនាំ "វី.ជី.ជី.ធី" | គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មនៃហប្រជាជាតិស្តីពីអភិបាលកិច្ចទទួលខុសត្រូវនៃការកាន់កាប់ដីធ្លី |

# ខ្លឹមសារសង្ខេប

នៅក្នុងទសវត្សរ៍ចុងក្រោយនេះ មានការទទួលស្គាល់យ៉ាងទូលំទូលាយថាអសុវត្ថិភាពនៃការកាន់កាប់ដីធ្លីមានផលប៉ះពាល់ទៅលើស្ត្រីជាពិសេសនៅក្នុងតំបន់ភាគខាងត្បូងនៃពិភពលោក ដែលជារឿយៗស្ត្រីភាគច្រើនគឺជាអ្នកមើលថែដ៏សំខាន់នៅក្នុងគ្រួសារ។ ដោយសារវិវាទដីធ្លីនៅតែជាបញ្ហាមួយក្នុងចំណោមបញ្ហាសិទ្ធិមនុស្សចម្បងៗជាច្រើននៅក្នុងប្រទេសកម្ពុជា ការលើកឡើងនេះសមនឹងការទទួលបាន នូវការយកចិត្តទុកដាក់ជាពិសេស។

ខណៈដែលការអភិវឌ្ឍវិជ្ជមានខ្លះ ប្រព្រឹត្តទៅនៅក្នុងលក្ខខណ្ឌសមភាពយែនឌ័រនៅកម្ពុជានាប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ប៉ុន្តែវិសមភាពយែនឌ័រនៅតែបន្តរីករាលដាលដល់ទំនាក់ទំនងសង្គមខ្មែរភាគច្រើន ជាពិសេសនៅតាមតំបន់ជនបទ។ ជាទូទៅ ស្ត្រីខ្មែរត្រូវបានរំពឹងថាបំពេញតួនាទីតាមប្រពៃណីពាក់ព័ន្ធនឹងភារកិច្ច ដែលស្ត្រីអាចបំពេញទៅបាននៅពេលដែលមានសុវត្ថិភាពនៃការកាន់កាប់ដីធ្លីតែប៉ុណ្ណោះ ដូចជាការផ្តល់ជម្រក និងចំណីអាហារសម្រាប់គ្រួសារ។ គឺដោយសារតែតួនាទីរបស់ស្ត្រីមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយនឹងដីធ្លី (ជាពិសេសនៅតាមតំបន់ជនបទ) មានហេតុផលច្បាស់លាស់ដែលថាស្ត្រីខ្មែរនឹងទទួលរងសម្ពាធយ៉ាងខ្លាំងពីវិវាទដីធ្លី ដែលកំពុងតែរីករាលដាលនៅកម្ពុជា ហើយការសន្មតនេះត្រូវបានគាំទ្រដោយការស្រាវជ្រាវតាមបែបគុណភាពដែលមានស្រាប់។[1] លើសពីនេះ នៅពេលប្រឈមនឹងការរីករាលដាលនៃការរំលោភបំពានដីធ្លី និងអវត្តមានក្នុងការការពារដីធ្លីរបស់ពួកគាត់ជាផ្លូវការ ជារឿយៗស្ត្រីខ្មែរស្ថិតនៅជួរមុខគេនៃចលនាតវ៉ានានាដើម្បី ការពារសិទ្ធិលើដីធ្លីរបស់ខ្លួន។[2]

តាមរយៈការវិភាគទិន្នន័យតាមបែបបរិមាណ ដែលប្រមូលបានពីស្ត្រីពាក់ព័ន្ធនៅក្នុងទំនាស់ដីធ្លីនៅទូទាំងប្រទេស របាយការណ៍នេះចង់បង្ហាញព័ត៌មានថ្មីអំពីរបៀបជាក់លាក់មួយចំនួនដែលស្ត្រីខ្មែរដែលទទួលរងផលប៉ះពាល់ដោយសារតែវិវាទដីធ្លី។

**ជំពូកទី ១ (សេចក្តីផ្តើម)** ផ្តល់នូវទិដ្ឋភាពទូទៅយ៉ាងសង្ខេបអំពីស្ថានភាពដីធ្លីនៅកម្ពុជាមុនឈានទៅ ពិនិត្យពីផលប៉ះពាល់ ដែលថាភាពលម្អៀងផ្នែកយែនឌ័រដែលមានស្រាប់ពីពេលមុននៅក្នុងសង្គមខ្មែរជះឥទ្ធិពលទៅលើទិដ្ឋភាពនៃការរំលោភបំពានសិទ្ធិដីធ្លីដែលអាចប៉ះពាល់ដល់ស្ត្រី។

---

[1] សូមមើល៖ អង្គការលីកាដូ ""ប្រពន្ធល្អ"៖ អ្នកធ្វើយុទ្ធនាការទាមទារដីធ្លីជាស្ត្រី និងផលប៉ះពាល់នៃភាពសកម្មផ្នែកសិទ្ធិមនុស្ស" (ឆ្នាំ ២០១៣) http://bit.ly/1MuL4FA និងអង្គការស្ត្រីខ្មែរ, របាយការណ៍អំពីផលប៉ះពាល់ខាងផ្នែកចិត្តសាស្ត្រសង្គមសាស្ត្រពីការបណ្តេញចេញពីដីធ្លីលើស្ត្រីនៅកម្ពុជា មានចំណងជើងថា "ពួកគេយកដីរបស់ខ្ញុំ ពួកគេយកជីវិតរបស់ខ្ញុំ" (ខែកុម្ភៈ ឆ្នាំ២០១៣) http://bit.ly/1Y1BXwK និងវិទ្យាស្ថានខ្មែរសម្រាប់សហប្រត្តិបត្តិការនិងសន្តិភាព"សន្តិសុខមនុស្សជាតិនិងសិទ្ធិដីធ្លីនៅកម្ពុជា"(ឆ្នាំ២០១៤)http://bit.ly/1VUGJ0B

[2] អង្គការលីកាដូ, ""ប្រពន្ធល្អ"៖ អ្នកធ្វើយុទ្ធនាការទាមទារដីធ្លីជាស្ត្រី និងផលប៉ះពាល់នៃភាពសកម្មផ្នែកសិទ្ធិមនុស្ស"(ឆ្នាំ ២០១៣)

**ជំពូកទី ២ (ក្របខណ្ឌគតិយុត្ត)** ពិនិត្យលើបទប្បញ្ញត្តិក្នុងច្បាប់ជាតិ និងអន្តរជាតិដែលផ្តល់ការការពារដល់សិទ្ធិដីធ្លីរបស់ស្ត្រី និងដែលផ្តល់ការការពារទល់នឹងអំពើហិង្សាក្នុងគ្រួសារ។

**ជំពូកទី ៣ (គោលបំណង និងវិធីសាស្ត្រ)** បរិយាយពីគោលបំណងនៃការស្រាវជ្រាវ និងវិធីសាស្ត្រដែលបានប្រើដើម្បីទទួលបានព័ត៌មានសម្រាប់របាយការណ៍នេះ។

**ជំពូកទី ៤ (ឥទ្ធិពលនៃវិវាទដីធ្លីទៅលើស្ត្រី)** បង្ហាញពីលទ្ធផលនៃការស្រាវជ្រាវដែលគាំទ្រជាលក្ខណៈទ្រឹស្តីដែលថាស្ត្រីរងផលប៉ះពាល់ក្នុងវិវាទដីធ្លីជាពិសេស។

**ជំពូកទី ៥ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍)** សង្ខេបអំពីរបកគំហើញចម្បងៗមួយចំនួនដែលបានពីការស្រាវជ្រាវ និងដោយផ្អែកលើលទ្ធផលនេះ ផ្តល់ជាអនុសាសន៍ជាក់លាក់ដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ ក្រុមហ៊ុននានា ព្រមទាំងម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល។

# ១. សេចក្តីផ្តើម

## ១.១ ទិដ្ឋភាពទូទៅពីស្ថានភាពដីធ្លីនៅកម្ពុជា

ប្រជាពលរដ្ឋខ្មែរភាគច្រើនពឹងផ្អែកលើដីធ្លីដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគាត់ ដែលក្នុងនោះ៧៩% រស់នៅតាមជនបទ[3] ហេតុដូច្នេះហើយធ្វើឱ្យពួកគាត់ពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើការកាន់កាប់ និងអាស្រ័យផលលើដី និងធនធានធម្មជាតិផ្សេងទៀត។ ប៉ុន្តែដោយសារតែប្រវត្តិសាស្ត្រច្របូកច្របល់របស់កម្ពុជាដែល បណ្តាលឱ្យមានការផ្លាស់ប្តូរជាច្រើនពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លី និងឯកសារដែលពាក់ព័ន្ធនឹងកម្មសិទ្ធិទាំងនោះប្រជាពលរដ្ឋជាច្រើនមិនមានប័ណ្ណកម្មសិទ្ធិដីធ្លីត្រឹមត្រូវ ហេតុដូចនេះហើយពួកគាត់ក្លាយជាជនងាយរងគ្រោះបំផុតពីការរំលោភយកដី។ នីតិរដ្ឋទន់ខ្សោយ និងការរីករាលដាលនៃអំពើពុករលួយបានជួយសម្រួលដល់ការរំលោភយកដីនិងធ្វើឱ្យមានភាពងាយរងគ្រោះកាន់តែច្រើនទៀត។ ដូច្នេះ អសុវត្ថិភាពនៃការកាន់កាប់ដីធ្លី គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាចម្បង និងក្តៅបំផុត ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ ជាពិសេសគឺស្ត្រី។

ប្រភពដ៏ចម្បងនៃវិវាទដីធ្លីនៅកម្ពុជាកើតឡើងដោយសារតែគោលនយោបាយផ្តល់ដីសម្បទានសេដ្ឋកិច្ចហួសហេតុពេក ដែលតាមរយៈគោលនយោបាយនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីជាង ២ លានហិចតាដើម្បីបម្រើដល់ផលប្រយោជន៍ឯកជន[4] ជាហេតុបង្កឱ្យមានការរំលោភយកដី ការបណ្តេញចេញដោយបង្ខំ និងការបំពានធ្ងន់ធ្ងរលើសិទ្ធិផ្សេងៗកើនឡើងយ៉ាងច្រើន។ ទោះបីជាដីជាច្រើនពាន់ហិចតាត្រូវបានដកហូតយកមកដាក់ក្រោមការគ្រប់គ្រងរបស់រដ្ឋវិញក្រោយពីលទ្ធផលនៃការសើរើទូទាំងប្រទេសលើសម្បទានដីសេដ្ឋកិច្ចបន្ទាប់ពីការផ្អាកផ្តល់ដីសម្បទានជាបណ្តោះអាសន្ននៅឆ្នាំ២០១២យ៉ាងណាក្តី បើយោងតាមរាជរដ្ឋាភិបាលកម្ពុជា គិតត្រឹមខែកក្កដា ឆ្នាំ ២០១៦ នៅមានក្រុមហ៊ុនចំនួន ២២៣ នៅកម្ពុជាដែលនៅតែបន្តកាន់កាប់សម្បទានដី សេដ្ឋកិច្ចលើផ្ទៃដីប្រហែល ១,៥ លានហិចតា។[5] បន្ថែមពីលើនេះ ការរំលោភយកដីពីសំណាក់អ្នកមានអំណាច និងតាមរយៈការផ្តួចផ្តើមគម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជាសម្បទានរុករករ៉ែ និងការសាងសង់ទំនប់វារីអគ្គិសនី បានបង្កឱ្យមានវិវាទដីធ្លីបន្ថែមទៀតនៅទូទាំងប្រទេស។

មានការប៉ាន់ប្រមាណថាប្រជាពលរដ្ឋខ្មែរយ៉ាងហោចណាស់ចំនួន ៧០ ម៉ឺននាក់ទទួលរងផលប៉ះពាល់ដោយសារវិវាទដីធ្លីនៅទូទាំងប្រទេសក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ[6] ហើយតួលេខនេះទំនងនឹង

---

[3] តួលេខរបស់ធនាគារពិភពលោក(World Bank) ឆ្នាំ២០១៤ http://bit.ly/1Y4NLxd

[4] ហ្វ្រីវ៉ាយហ្សេរ និង ណារ៉េន (Vrieze & Naren) "ការបែងចែកកម្ពុជាជាបំណែក ៖ ការផ្តល់សម្បទានក្នុងពេលតែមួយ" *ឌឹខេមបូឌា ដេលី* ខែមិនា២០១២http://bit.ly/1Rw8z32

[5] ម៉ៃ ទិត្យធារ៉ា "ក្រសួងប្រកាសអំពីចំណូលបានពីពន្ធលើសម្បទានដីសេដ្ឋកិច្ច" *សារព័ត៌មានខ្មែរថាមស៍* (ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦) http://bit.ly/2a3U6am

[6] អង្គការឃ្លាំមើលសិទ្ធិមនុស្ស, "កម្ពុជា៖ យុទ្ធនាការផ្តល់ប្លង់កម្មសិទ្ធិដីធ្លីធ្វើឱ្យមានការរំលោភបំពាន" (ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៣) http://bit.ly/17FLZsD

មានចំនួនកើនឡើងនៅប៉ុន្មានឆ្នាំខាងមុខដោយមានវិវាទថ្មីៗទៀតកំពុងកើតមានឡើងជាបន្តបន្ទាប់ និងគ្មានដំណោះស្រាយណាមួយលើវិវាទដែលមានស្រាប់ជាច្រើន ដោយសារតែយន្តការដោះស្រាយវិវាទដីធ្លីដែលមានស្រាប់ពុំមានប្រសិទ្ធភាពច្រើនក្នុងការបញ្ចប់វិវាទនោះទេ។[7]

## ១.២ ស្ត្រី និងសុវត្ថិភាពកាន់កាប់ដីធ្លី

ការទទួលបានដីធ្លី និងធនធានធម្មជាតិផ្សេងទៀតរបស់ស្ត្រី គឺជាកត្តាសំខាន់ក្នុងការធានាសមភាពយេនឌ័រ និងកម្រិតជីវភាពគ្រប់គ្រាន់។[8] ការស្រាវជ្រាវបានបង្ហាញថាជាលទ្ធផលនៃការកើនឡើងនៃសុវត្ថិភាពកាន់កាប់ដីធ្លីរបស់ស្ត្រី នាំឱ្យការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងគ្រួសារកើនឡើង ចំណូលក្នុងគ្រួសារកើនឡើង អំពើហិង្សាក្នុងគ្រួសារថយចុះ និងចំណាយលើថ្លៃម្ហូបអាហារ និងការសិក្សារបស់កូនៗមានការកើនឡើង។[9] លទ្ធផលពីការស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់ នៅក្នុងបរិបទកម្ពុជាដែលនៅតែមានភាពលម្អៀងផ្នែកយេនឌ័រជាខ្លាំង ហើយដូចនេះ សមត្ថភាពរបស់ស្ត្រីក្នុងការបំពេញតួនាទីដែលពួកគាត់ត្រូវធ្វើគឺពឹងផ្អែកទាំងស្រុងលើសុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់គាត់។

នៅក្នុងសង្គមខ្មែរ ខណៈដែលការបង្រៀនពីក្រមសីលធម៌ប្រពៃណីដែលគេស្គាល់ថាជា *"ច្បាប់ស្រី"* ទៅឱ្យសិស្សសាលាជាស្ត្រីត្រូវបានដាក់កម្រិតមួយចំនួននៅប៉ុន្មានឆ្នាំចុងក្រោយនេះ[10] គោលការណ៍នៃការចេះស្តាប់បង្គាប់របស់ក្មេងស្រីនៅតែបន្តបញ្ជាក់ពីទស្សនៈដ៏ផ្ទុយផង់របស់ស្ត្រីខ្មែរ។ បុរស និងស្ត្រី គឺមានតួនាទីទៅតាមគោលការណ៍យេនឌ័រ ដោយអនុលោមទៅតាមជំនឿវប្បធម៌ និងទំនៀមទម្លាប់យ៉ាងមុតមាំ ដែលបញ្ជាក់ឡើងវិញពីការបែកចែករវាងភាពជាបុរសមានអំណាចខ្លាំងក្លា និងភាពជានារីភេទទន់ខ្សោយ។ ដូច្នេះ ដោយហេតុថាសភាព ទន់ខ្សោយ និងមានមនោសញ្ចេតនារបស់ស្ត្រីនេះ មានការរំពឹងថាស្ត្រីបំពេញតួនាទីជាអ្នកមើលថៃ និងអ្នកការពារគ្រួសារជាបឋម។

ភស្តុតាងជាច្រើនអះអាងថាភាពលម្អៀងខាងយេនឌ័រនៅក្នុងប្រទេសកម្ពុជា បានធ្វើឱ្យស្ត្រីកំពុងទទួលរងយ៉ាងវិសមាមាត្រដោយសារវិវាទដីធ្លី ដោយភ្ជាប់រវាងវិវាទដីធ្លី អំពើហិង្សាក្នុងគ្រួសារ និងការបែកបាក់គ្រួសារដែលគេមើលឃើញយ៉ាងច្បាស់។ ជាឧទាហរណ៍តាម របាយការណ៍ស្តីពី *"ប្រពន្ធល្អ"* របស់អង្គការលីកាដូ បានអះអាងថានៅពេលដែលស្ត្រីបោះបង់តួនាទីជាមេផ្ទះដែលមានជាយូរមកហើយនោះដើម្បីចាប់ផ្តើមធ្វើយុទ្ធនាការ

---

[7]សម្រាប់ព័ត៌មានបន្ថែមពីភាពបរាជ័យនៃយន្តការដោះស្រាយទំនាស់ សូមមើល៖ ម.ស.ម.ក, "ភាពបរាជ័យនៃយន្តការដោះស្រាយវិវាទដីធ្លី" (កំណត់ត្រាសង្ខេប) (ខែ កក្កដា ឆ្នាំ ២០១៤) http://bit.ly/12zx4nE

[8] ភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី, "ការយល់ដឹងពីសិទ្ធិដីធ្លី និងផលិតភាពធនធានផ្សេងទៀតរបស់ស្ត្រី" (ឆ្នាំ ២០១៣) http://bit.ly/1h09eJR

[9] ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ "ការកាន់កាប់ដីធ្លី សិទ្ធិលើទ្រព្យសម្បត្តិ និងយេនឌ័រ៖ បញ្ហាប្រឈម និងវិធីសាស្ត្រសម្រាប់ពង្រឹងការកាន់កាប់ដីធ្លី និងសិទ្ធិលើទ្រព្យសម្បត្តិរបស់ស្ត្រី"(អត្ថបទសង្ខេប) (ខែកក្កដា ឆ្នាំ ២០១៣) http://bit.ly/29qAwbN

[10] យៃលី គ្រែស និង អេង សុធី, "គ្មានទេកន្លែងសម្រាប់" "ច្បាប់ស្រី" នៅក្នុងសាលារៀនខ្មែរ" *សារព័ត៌មាន ឌឹខេមបូឌា ដេលី* (ចុះថ្ងៃទី៩ខែមិថុនា ឆ្នាំ ២០១៥) http://bit.ly/1MPseWY

ទាមទារសុវត្ថិភាពកាន់កាប់ដីធ្លីប្រសើរជាងមុន និងការសម្រេចចិត្តដែលកើតចេញពីសម្ពាធវប្បធម៌ទៅលើម្ដាយ ដែលត្រូវផ្ដល់ម្ហូបអាហារ និងជម្រកដល់គ្រួសាររបស់ពួកគេ ធ្វើឱ្យអំពើហិង្សាក្នុងគ្រួសារកើនឡើងផងដែរ។ របាយការណ៍ស្ដីពី "*សុវត្ថិភាពមនុស្សជាតិ និងសិទ្ធិដីធ្លីនៅកម្ពុជា*" របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាពបានគាំទ្របន្ថែមពីលើរបកគំហើញនៃរបាយការណ៍របស់អង្គការលីកាដូ ដោយរបាយការណ៍នេះ បានរកឃើញថាករណីអំពើហិង្សាក្នុងគ្រួសារបានកើនឡើងនៅក្នុងពេលមានវិវាទដីធ្លី។[11]

លើសពីនេះទៀត លទ្ធផលពីការស្រាវជ្រាវបានអះអាងថាខណៈដែលស្ត្រីជារឿយៗត្រូវបានជំរុញឱ្យធ្វើសកម្មភាពកាន់តែសកម្ម ដើម្បីការពារដីធ្លីរបស់ពួកគាត់ក្នុងការធានាថាកូនៗរបស់ពួកគាត់មានផ្ទះនៅស្ថិតស្ថេរ ប៉ុន្តែការធ្វើយុទ្ធនាការជារឿយៗធ្វើឱ្យស្ត្រីបាត់បង់ពេលវេលា ដែលគាត់ត្រូវចំណាយពេលរកប្រាក់ចំណូល និងមើលថែទាំកូនៗនោះទៅវិញ។ ដោយឡែក ការបាត់បង់ចំណូលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ ដែលអាចធ្វើឱ្យគ្រួសារមិនមានលទ្ធភាពបង់ថ្លៃថ្នាំចាំបាច់ និងបង់ថ្លៃសាលាកូនរៀន ជាដើម។ អង្គការលីកាដូបានរកឃើញថាភាពសកម្មរបស់ស្ត្រីអាចផ្ដល់លទ្ធផលផ្ទុយគឺជា "*ប្រភពនៃទំនាស់ផ្ទៃក្នុងគួរឱ្យកត់សម្គាល់ សម្រាប់ស្ត្រីគ្រប់រូបដោយសារតែមូលហេតុចម្បងក្នុងការទទួលយកតួនាទីធ្វើយុទ្ធនាការគឺដើម្បីផ្ដល់ជីវិតល្អដល់កូនដោយធានាថាពួកគេមានផ្ទះសម្បែងនៅនាពេលបច្ចុប្បន្ន និងនាពេលអនាគត*"។[12]

---

[11] អង្គការលីកាដូ, ""ប្រពន្ធល្អ"៖ អ្នកធ្វើយុទ្ធនាការទាមទារដីធ្លីជាស្ត្រី និងផលប៉ះពាល់នៃភាពសកម្មផ្នែកសិទ្ធិមនុស្ស"(ឆ្នាំ២០១៣) http://bit.ly/1MuL4FA និង វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាព "សន្តិសុខមនុស្សជាតិ និងសិទ្ធិដីធ្លីនៅកម្ពុជា" (ឆ្នាំ២០១៤) http://bit.ly/1VUGJ0B

[12] អង្គការលីកាដូ ""ប្រពន្ធល្អ"៖ អ្នកធ្វើយុទ្ធនាការទាមទារដីធ្លីជាស្ត្រី និងផលប៉ះពាល់ពីភាពសកម្មផ្នែកសិទ្ធិមនុស្ស" (ខែ វិច្ឆិកា ឆ្នាំ ២០១៤) http://bit.ly/1MuL4FA

# ២. ក្របខណ្ឌគតិយុត្តិ

ដោយហេតុថាវិវាទដីធ្លីមានសក្តានុពលធ្វើឱ្យប៉ះពាល់ជាពិសេសដល់ស្ត្រី ជាការសំខាន់ណាស់ដែលត្រូវមានប្រព័ន្ធការពារតាមផ្លូវច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់ពួកគាត់។ តាមទ្រឹស្តី ដោយអនុលោមតាមច្បាប់ជាតិ មានការកំណត់ពីវិធានការការពារយ៉ាងច្រើនដែលការពារសិទ្ធិដីធ្លីបន្ថែមពីលើសិទ្ធិស្ត្រីផ្សេងទៀត ក៏ប៉ុន្តែដោយសារការអនុវត្តមានភាពទន់ខ្សោយ តាមជាក់ស្តែងសិទ្ធិទាំងនេះជារឿយៗមិនត្រូវបានការពារនោះទេ។

ជាច្រើនលើកច្រើនសារ ម.ស.ម.ក ធ្លាប់បានលើកឡើងពីការប្តេជ្ញាតាមផ្លូវច្បាប់របស់កម្ពុជាលើបញ្ហាសិទ្ធិមនុស្ស រួមទាំងសិទ្ធិដីធ្លីទាំងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ដោយឡែក សលាកប័ត្រព័ត៌មានរបស់ ម.ស.ម.ក ស្តីពី "ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅកម្ពុជា"[13] គូសបញ្ជាក់ពីការអនុវត្តប្រកពចម្បងៗនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងប្រព័ន្ធគតិយុត្តិកម្ពុជា និងរបាយការណ៍របស់ ម.ស.ម.ក ស្តីពី "កម្ពុជា៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី"[14] បានផ្តល់នូវការវិភាគអំពីក្របខណ្ឌគតិយុត្តិ ដែលការពារសិទ្ធិដីធ្លីនិងកាតព្វកិច្ចតាមផ្លូវច្បាប់របស់កម្ពុជាក្នុងការធានាសុវត្ថិភាពកាន់កាប់ដីធ្លី។

ហេតុដូច្នេះ ជំពូកនេះនឹងផ្តោតជាពិសេសទៅលើសិទ្ធិស្ត្រីនៅកម្ពុជាដោយធ្វើការពិនិត្យលើបទប្បញ្ញត្តិពាក់ព័ន្ធក្រោមច្បាប់ជាតិ និងអន្តរជាតិ ជាពិសេសពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងអំពើហិង្សាក្នុងគ្រួសារ ដោយបានរកឃើញថាអំពើហិង្សាជាបញ្ហាសំខាន់មួយដែលស្ត្រីខ្មែរពាក់ព័ន្ធនឹងនៅក្នុងវិវាទដីធ្លីកំពុងជួបប្រទះ។

## ២.១ ការការពារសិទ្ធិលើដីធ្លីរបស់ស្ត្រី

### *២.១.១ ការការពារក្រោមច្បាប់អន្តរជាតិ*

សិទ្ធិស្ត្រីក្នុងការទទួលបានដីធ្លី និងធនធានធម្មជាតិផ្សេងទៀតត្រូវបានការពារស្របតាមច្បាប់អន្តរជាតិ ដូច្នេះក៏ត្រូវទទួលបានការការពារដោយស្វ័យប្រវត្តិក្រោមច្បាប់ជាតិតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា("រដ្ឋធម្មនុញ្ញ")ដែលបានបញ្ចូលច្បាប់សិទ្ធិមនុស្សអន្តរជាតិយ៉ាងច្បាស់លាស់ក្នុងច្បាប់ជាតិ។[15]

មាត្រា ២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ប.ស.ស") កំណត់ពីគោលការណ៍នៃការមិនរើសអើង រួមទាំងផ្នែកយេនឌ័រក្នុងការទទួលបានសិទ្ធិដែលធានានៅក្នុង ស.ប.ស.ស និងជាពិសេស មាត្រា ១៧ នៃ ស.ប.ស.ស ចែងថា "*មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ (និង)*

---

[13] ម.ស.ម.ក "ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅកម្ពុជា" (ខែមករា ឆ្នាំ ២០១៤) http://bit.ly/1rMhUc2

[14] ម.ស.ម.ក "កម្ពុជា៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី" (ខែធ្នូ ឆ្នាំ ២០១៣) http://bit.ly/1KtPNVy

[15] ដោយមានការបញ្ជាក់ពីក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈសេចក្តីសម្រេចលេខ 092/003/2007 (ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧)

*គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ។"*[16] ដូចគ្នានេះដែរ សិទ្ធិស្ត្រីក្នុងការមានកម្មសិទ្ធិ និងគ្រប់គ្រងទ្រព្យសម្បត្តិដោយគ្មានការរើសអើងត្រូវបានការពារស្របតាមមាត្រា ១៥ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ("ស៊ីដ័រ") ដែលកម្ពុជាជារដ្ឋភាគីនៃអនុសញ្ញានេះ។ ដោយពាក់ព័ន្ធជាពិសេស ស៊ីដ័រ ក៏អំពាវនាវឱ្យរដ្ឋភាគី *"ត្រូវគិតគូរដល់បញ្ហាពិសេសដែលស្ត្រីនៅជនបទប្រឈមមុខ និងតួនាទីសំខាន់របស់ស្ត្រីជនបទក្នុងការរក្សាភាពគង់វង្សសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន"*[17] និងតម្រូវឱ្យមានការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ *"ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ដើម្បីធានានូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍជនបទ និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍជនបទ។"*[18] ដោយឡែកស្ត្រីជនបទត្រូវបានធានានូវសិទ្ធិស្មើគ្នាក្នុងការទទួលបានលក្ខខណ្ឌរស់នៅគ្រប់គ្រាន់ រួមទាំងការមានទីលំនៅដ្ឋានផងដែរ។[19]

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ("ក.អ.ស.ស.វ") ដែលកម្ពុជាជារដ្ឋ ភាគីដែរនោះ បានអំពាវនាវឱ្យរដ្ឋភាគីទាំងអស់ធានានូវសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការទទួលបានសិទ្ធិទាំងអស់ដែលមានចែងនៅក្នុង ក.អ.ស.ស.វ[20] ដោយហាមការរើសអើងណាមួយលើផ្អែកភេទ[21] និងទទួលស្គាល់សិទ្ធិក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ រួមទាំងការមានទីលំនៅដ្ឋាន។[22]

ទោះបីជាគ្មានការចងកាតព្វកិច្ចតាមផ្លូវច្បាប់យ៉ាងណាក្តី គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិស្តីពីអភិបាលកិច្ចទទួលខុសត្រូវ នៃការកាន់កាប់ដីធ្លី ជ.ល.ផ.ល និងព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀងអាហារជាតិ ("គោលការណ៍ណែនាំ វី.ជី.ជី.ធី") រួមបញ្ចូលនូវសមភាពយែនឌ័រថាជាគោលការណ៍សំខាន់មួយក្នុងចំណោមគោលការណ៍ទាំង ១០ ដើម្បីអនុវត្តអភិបាលកិច្ចទទួលខុសត្រូវនៃការកាន់កាប់ដីធ្លី និងសង្កត់ធ្ងន់លើការយកចិត្តទុកដាក់ផ្នែកយែនឌ័រនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការអភិបាលកិច្ច។ គោលការណ៍ណែនាំ វី.ជី.ជី.ធី គឺជាបណ្តុំគោលការណ៍ដែលទទួលស្គាល់ និងទទួលយកជាលក្ខណៈអន្តរជាតិ ព្រមទាំងជាការអនុវត្តល្អបំផុតនៅក្នុងការណែនាំដល់ការអភិវឌ្ឍ និងការអនុវត្ត គោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លី និងអភិបាលកិច្ចលើធនធាន។

---

16 មាត្រា១៧នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(ថ្ងៃទី១០ខែធ្នូឆ្នាំ១៩៤៨) http://bit.ly/2bmH8e9

17មាត្រា១៤(១)នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី(ថ្ងៃទី១៨ខែធ្នូ១៩៧៩) http://bit.ly/1jEADx3

18 មាត្រា ១៤(២) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី http://bit.ly/1jEADx3

19 មាត្រា ១៤(២)(ជ) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី http://bit.ly/1jEADx3

20 មាត្រា ៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌

21 មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌

22 មាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌

### ២.១.២ ការការពារក្រោមច្បាប់ជាតិ

ដូចបានបញ្ជាក់រួចមកហើយ សិទ្ធិ និងការការពារជាអន្តរជាតិដែលបានរៀបរាប់ខាងលើអាចយកមកអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិតាមរយៈរដ្ឋធម្មនុញ្ញ ប៉ុន្តែក៏មានបទប្បញ្ញត្តិជាក់លាក់នៅក្នុងច្បាប់ជាតិដែលផ្តល់ការការពារបន្ថែមលើសិទ្ធិមានដីធ្លីរបស់ស្ត្រីផងដែរ។ ច្បាប់ភូមិបាលឆ្នាំ ២០០១ លើកឡើងពីទស្សនៈទាននៃសហកម្មសិទ្ធិលើទ្រព្យសម្បត្តិរួមគ្នាក្នុងជំពូកទី ៩ ដែលត្រូវបានបកប្រែពីអត្ថបទខ្មែរថាជា *"កម្មសិទ្ធិអវិភាគ"* ដែល *"កម្មសិទ្ធិករអវិភាគម្នាក់ៗអាស្រ័យផលលើទ្រព្យ និងប្រើប្រាស់ទ្រព្យក្នុងព្រំដែនដែលមិនត្រូវប៉ះពាល់ដល់សិទ្ធិនៃកម្មសិទ្ធិករអវិភាគឯទៀត"*។[23] លើសពីនេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមរដ្ឋប្បវេណី") ដែលបានអនុម័តនៅឆ្នាំ ២០១១ មានចែងពីបទប្បញ្ញត្តិដែលផ្តល់វិធានការការពារបន្ថែមដល់សិទ្ធិស្ត្រី *"ក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម"*។[24] ដើម្បីលក់ទ្រព្យសម្បត្តិដែលមានកម្មសិទ្ធិរួមគ្នាប្តីប្រពន្ធទាំងពីរត្រូវតែយល់ព្រម។ ប៉ុន្តែករណីនេះសំដៅលើទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ និងមិនត្រូវអនុវត្តចំពោះទ្រព្យសម្បត្តិដោយឡែកដែលជាកម្មសិទ្ធិរបស់សហព័ទ្ធម្ខាងទៀតមុនពេលមានចំណងអាពាហ៍ពិពាហ៍នោះទេ។ បន្ថែមពីនេះ ស្របតាមមាត្រា ៤៦នៃរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចផ្តល់ជំនួយដល់ *"នារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជម្ងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ។"*

## ២.២ ការការពារប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ

### ២.២.១ ការការពារក្រោមច្បាប់អន្តរជាតិ

អំពើហិង្សាក្នុងគ្រួសារត្រូវបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិថាជាការរំលោភបំពានសិទ្ធិមនុស្ស។ ខណៈដែល ស៊ីដ័រ មិនបានចែងឱ្យបានច្បាស់អំពីអំពើហិង្សាលើស្ត្រី ឬអំពើហិង្សាក្នុងគ្រួសារក្តី ប៉ុន្តែសិទ្ធិស្មើគ្នា និងសេរីភាពរួចផុតពីការរើសអើងដែលការពារក្រោម ស៊ីដ័រ ត្រូវបានបកស្រាយថាជាការការពារប្រឆាំងនឹងអំពើហិង្សាបែបនោះ។[25] លើសពីនេះ មាត្រា ៥ នៃ ស៊ីដ័រ ទាមទារឱ្យរដ្ឋភាគីធ្វើការយ៉ាងសកម្មក្នុងការលុបបំបាត់ការអនុវត្តទាំងពីរដែលផ្អែកលើតួនាទីយែនឌ័រតាមទម្លាប់ និងឥរិយាបថវប្បធម៌ និងសង្គមដែលបង្កប់នូវគំនិតដែលថាភេទណាអន់ជាង ឬប្រសើរជាង ដែលការលុបបំបាត់នេះមានសារៈសំខាន់ជាពិសេសនៅក្នុងបរិបទ កម្ពុជា។ បន្ថែមពីលើនេះ គណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រី ដែលជាស្ថាប័នតាមដានការអនុវត្តស៊ីដ័រ និងអាចចេញការបកស្រាយបែបបង្គាប់បញ្ជាលើបទប្បញ្ញត្តិនៃ ស៊ីដ័រ ដែលបានអនុម័តនៅក្នុងអនុសាសន៍ទូទៅ

---

[23] មាត្រា ១៧១ នៃច្បាប់ភូមិបាល

[24] មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា http://bit.ly/29QGGid

[25] គណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រី, កថាខណ្ឌទី ៦ និង ៧ នៃអនុសាសន៍ទូទៅលេខ ១៩ (ឆ្នាំ ១៩៩២) http://bit.ly/1pIe2Cz

លេខ១៩ ឆ្នាំ១៩៩២ ដែលរួមបញ្ចូលយ៉ាងច្បាស់នូវអំពើហិង្សាទាក់ទងនឹងយេនឌ័រថាជាទម្រង់នៃការរើសអើង ដែលគ្របដណ្តប់ដោយ ស៊ីដ័រ បានប្រកាសថ្កោលទោសអំពើហិង្សាក្នុងគ្រួសារថាជា *"ទម្រង់គ្រោះថ្នាក់បំផុតនៃអំពើហិង្សាប្រឆាំងនារីភេទ"*។[26] បន្ថែមលើការផ្តល់សច្ចាប័នលើ ស៊ីដ័រ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមរបស់ ស៊ីដ័រ ដែលផ្តល់សិទ្ធិឱ្យបុគ្គលក្នុងការប្តឹងទៅគណៈកម្មាធិការ ដែលនេះជាការចង្អុលបង្ហាញបន្ថែមពីការប្តេជ្ញាចិត្តក្នុងការការពារស្ត្រី។

បន្ថែមពីលើនេះ សន្ធិសញ្ញា និងអនុសញ្ញាផ្សេងទៀតមួយចំនួនត្រូវបានបកស្រាយថាមានចែងពីបញ្ញត្តិហាមឃាត់អំពើហិង្សាក្នុងគ្រួសារ ទោះបីជាបញ្ញត្តិទាំងនោះមិនបានចែងឱ្យបានច្បាស់អំពីអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាលើស្ត្រីក្តី។ ជាឧទាហរណ៍ ស.ប.ស.ស ចែងថា *"បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និង សន្តិសុខផ្ទាល់ខ្លួន"*[27] សិទ្ធិនេះត្រូវបានអះអាងសារជាថ្មីនៅក្នុងមាត្រា ៦ និង ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ ដូចគ្នានេះដែរ សិទ្ធិរួចផុតពីការធ្វើទារុណកម្មគឺពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារដែលការពារដោយ ស.ប.ស.ស[28] ក.អ.ស.ព.ន[29] និងអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មនិងការប្រព្រឹត្តមកលើខ្លួន ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដែលកម្ពុជាជារដ្ឋភាគី។

## ២.២.២ ការការពារក្រោមច្បាប់ជាតិ

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥ ("ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ") ផ្តល់នូវនិយមន័យអំពើហិង្សាក្នុងគ្រួសារដែលប្រើប្រាស់កើត និងខណៈដែលច្បាប់នេះមិនបានចែងពីបទប្បញ្ញត្តិស្តីពីបទល្មើសព្រហ្មទណ្ឌ ឬទោសប្បញ្ញត្តិជាក់លាក់ក្តី នៅក្នុងមាត្រា ៣៥ ចែងថាអំពើហិង្សាក្នុងគ្រួសារទាំងឡាយណាដែលចាត់ទុកជាបទល្មើសព្រហ្មទណ្ឌត្រូវ *"ផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន"*។[30] ប៉ុន្តែ នេះមានន័យថាអំពើហិង្សាក្នុងគ្រួសារអាចត្រូវផ្តន្ទាទោសបាន លុះត្រាតែមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលកំណត់អំពើទាំងនោះថាជាបទល្មើស ដែលមានន័យថាបទល្មើសខ្លះដូចជាអំពើហិង្សាផ្លូវចិត្ត មិនត្រូវបានផ្តន្ទាទោសនោះទេ។ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ក៏មិនត្រូវបានចាត់បញ្ចូលនៅក្នុងច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារផងដែរក៏ដូចជាអំពើហិង្សាផ្នែកសេដ្ឋកិច្ច ដែលសំដៅលើអំពើទាំងឡាយណាដែលមានបំណងកាត់បន្ថយលទ្ធភាពរបស់ស្ត្រីក្នុងការបង្កើន

---

[26] គណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រី, អនុសាសន៍ទូទៅលេខ ១៩ (ឆ្នាំ ១៩៩២) ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី (CEDAW) http://bit.ly/1pIe2Cz

[27] មាត្រា ៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)

[28] មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

[29] មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[30] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ(ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៥) http://bit.ly/1UytI2Z

ប្រាក់ចំណូលរបស់ខ្លួន និង/ឬកម្រិតជីវភាពរស់នៅ។ ការមិនមានចែងពីទម្រង់នៃអំពើហិង្សាទាំងនេះនៅក្នុងច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារជាការអនុវត្ត ផ្ទុយដោយផ្ទាល់ទៅនឹង ស៊ីដ័រ។

ការខកខានរបស់ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីការការពារជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារឱ្យបានគ្រប់គ្រាន់មានលក្ខណៈកាន់តែអាក្រក់ដោយសារតែការយល់ដឹងមានកម្រិតរបស់ច្បាប់នេះចំពោះបុគ្គលដែលអាចចាត់ទុកថាជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។ ច្បាប់ នេះបានកំណត់ជនរងគ្រោះថាជាប្តីប្រពន្ធ កូនក្នុងបន្ទុក ឬ *"ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ"*។[31] តាមរយៈការកំណត់ព្រំដែនឱ្យកាន់តែតូចចង្អៀតអំពីអត្ថន័យជាជនរងគ្រោះ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារជៀសមិនផុតពីការខកខានក្នុងការការពារស្ត្រីនៅក្នុងទំនាក់ទំនងមិនផ្លូវការជាមួយបុរស ដូចជាស្រីកំណាន់ និងអតីតភរិយា ដែលងាយនឹងទទួលការបំពានដែរ។

មាត្រា ៨ នៃច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារគឺជាមូលហេតុនៃក្តីបារម្ភមួយផ្សេងទៀតដោយហេតុដែលថាវាអាចមើលឃើញថាមានការអនុញ្ញាតឱ្យមានអំពើហិង្សាក្នុងគ្រួសារក្នុងរូបភាពជា *"ការដាក់វិន័យ"* ។ មាត្រានេះលើកលែងការដាក់ទោសដែលជាការលើកទឹកចិត្តសហព័ទ្ធ កូន ឬអ្នកនៅក្នុងបន្ទុក *"ឱ្យដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់"* ចេញពីការចាត់ថ្នាក់បញ្ចូលថាជាអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើអំពើនោះ *"អនុលោមតាមគោលការណ៍នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមារ"*។ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារក៏ខកខានមិនគិតគូរពីការការពារខ្លួនផងដែរ។ ជាលទ្ធផល ស្ត្រីជាច្រើនត្រូវជាប់ពន្ធនាគារពីការសម្លាប់ប្តីរបស់ខ្លួនដោយសារតែតបតនឹងអំពើហិង្សាក្នុងគ្រួសារ ដោយតុលាការមិនបានចាត់ទុកថាជាមូលហេតុនៃការការពារខ្លួននោះទេ។

កាលពីខែកក្កដា ឆ្នាំ ២០១៦ ក្រសួងកិច្ចការនារីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយនឹងភ្នាក់ងារអង្គការសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) ដែលជាចំណុចចាប់ផ្តើម នៃការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារឡើងវិញ។ អ្នកនាំពាក្យក្រសួង លោក ផុន ពុធបូរី បានថ្លែងថា *"គោលបំណងនៃការត្រួតពិនិត្យនេះគឺដើម្បីបំពេញភាពខ្វះចន្លោះនិងបង្កើនប្រសិទ្ធភាពនៃការឆ្លើយតបទៅនឹងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ"*។[32] ការត្រួតពិនិត្យនេះមិនច្បាស់ថានឹងប្រព្រឹត្តទៅយូរប៉ុណ្ណាណានោះទេ។

---

[31] មាត្រា ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

[32] សូននៀ គូសបាចឈ័រ (Sonia Kohlbacher) "ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដែលមានភាពចម្រូងចម្រាសស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាល" *សារព័ត៌មាន ឌឹ ខេមបូឌា ដេលី* (ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៦) http://bit.ly/2bsRWrm

ក្រមរដ្ឋប្បវេណីចែងពីលក្ខខណ្ឌដែលស្ត្រីអាចដាក់ពាក្យប្តឹងសុំលែងលះនៅក្នុងមាត្រា ៩៧៨ ក្នុងករណីគ្មានការព្រមព្រៀងលែងលះ។[33] គួរឱ្យសោកស្តាយ មាត្រានេះមិនបានចែងឱ្យបានច្បាស់ថាអំពើហិង្សាក្នុងគ្រួសារជាមូលដ្ឋានតាមផ្លូវច្បាប់ដើម្បីសុំលែងលះនោះទេ។

[33] មាត្រា ៩៧៨ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

# ៣. គោលបំណង និងវិធីសាស្ត្រ

## ៣.១ គោលបំណង

ដូចបានបង្ហាញរួចមកហើយថា ការសិក្សាស្រាវជ្រាវមួយចំនួននាពេលថ្មីៗនេះបានស្រាវជ្រាវលើករណីជីវិតរបស់ស្ត្រីនៅកម្ពុជាទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារវិវាទដីធ្លី។ ក៏ប៉ុន្តែដោយសារតែវិសាលភាពមានកម្រិតនៃការសិក្សាស្រាវជ្រាវទាំងនោះ (ពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើទិន្នន័យតាមបែបគុណភាព) ការសិក្សាស្រាវជ្រាវទាំងនោះមិនបានផ្តល់សេចក្តីសន្និដ្ឋានដាច់ស្រេចនោះទេ។ ដូចនេះ គម្រោងកម្មវិធីកំណែទម្រង់ដីធ្លីបានកំណត់ពីតម្រូវការដែលត្រូវស្រាវជ្រាវបន្ថែមលើការស្រាវជ្រាវដែលមានពីមុនមកស្រាប់នៅក្នុងវិស័យនេះ ក៏ដូចជាលទ្ធផលពីការស្រាវជ្រាវពីមុនរបស់ ម.ស.ម.ក ផ្ទាល់ ជាពិសេស គឺ*កម្រងជីវប្រវត្តិរបស់សកម្មជនដីធ្លី*របស់ ម.ស.ម.ក[34] ដែលបានចងក្រងអំពីជីវប្រវត្តិរបស់ស្ត្រីមួយចំនួនដែលទទួលរងផលប៉ះពាល់ក្នុងវិវាទដីធ្លី។ គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីកាត់បន្ថយគម្លាតរវាងការស្រាវជ្រាវបែបគុណភាពបឋម និងរបកគំហើញពិតប្រាកដតាមរយៈការប្រមូលផ្តុំកម្រងទិន្នន័យតាមបែបបរិមាណជាច្រើន ដែលដកស្រង់ចេញពីចំនួនសំណាកតាមបែបតំណាង។

## ៣.២ វិធីសាស្ត្រ

ការស្រាវជ្រាវឯកសារដែលមានស្រាប់ជាច្រើន និងការពិភាក្សាជាមួយក្រុមដែលបានសម្របសម្រួលដោយគម្រោងកម្មវិធីកំណែទម្រង់ដីធ្លី កាលខែមីនា ឆ្នាំ ២០១៦ គឺជាមូដ្ឋានស្រាវជ្រាវបឋមសម្រាប់សរសេររបាយការណ៍នេះ។ ការសិក្សាទាំងពីរនេះបានបង្ហាញថាសុខភាពផ្លូវចិត្តមិនល្អ ការញៀនជាតិស្រវឹង និងការបដិសេធរបស់ប្តីឱ្យប្រពន្ធចូលរួមនៅក្នុងយុទ្ធនាការទាមទារ ជាបញ្ហាគួរឱ្យបារម្ភ ៣ ក្នុងចំណោមស្ត្រីដែលទទួលរងផលប៉ះពាល់ដោយសារវិវាទដីធ្លី។ ដូច្នេះ ការស្ទង់ដែលធ្វើឡើងសម្រាប់ផ្តល់ទិន្នន័យសំខាន់ៗ សម្រាប់ផ្តល់ជាលទ្ធផលស្រាវជ្រាវជាក់លាក់នៅក្នុងរបាយការណ៍នេះត្រូវបានរៀបចំឡើង សម្រាប់ឆ្លុះបញ្ចាំងលទ្ធផលនៃការស្រាវជ្រាវដំបូង។

នៅក្នុងបញ្ជីស្ទង់មតិ មានពហុសំណួរជ្រើសរើសភាគច្រើន ដែលចែកចេញជា ៧ ផ្នែកដូចជា៖ ព័ត៌មានពីជីវប្រវត្តិ ព័ត៌មានទូទៅពីវិវាទដីធ្លី ផលប៉ះពាល់លើផ្នែកសេដ្ឋកិច្ចដោយសារវិវាទដីធ្លី ផលប៉ះពាល់ដោយសារវិវាទដីធ្លីលើទំនាក់ទំនងក្នុងគ្រួសារ ផលប៉ះពាល់ដោយសារវិវាទដីធ្លីលើសុខភាពផ្លូវចិត្តរបស់អ្នកផ្តល់សម្ភាសន៍ ផលប៉ះពាល់ដោយសារវិវាទដីធ្លីលើកូនៗរបស់អ្នកផ្តល់ការសម្ភាសន៍ និងភាពសកម្មរបស់អ្នកផ្តល់សម្ភាសន៍។ ការស្ទង់មតិត្រូវបានធ្វើសាកល្បងជាមួយអ្នកចូលរួមនៅក្នុងរាជធានីភ្នំពេញដើម្បីពិនិត្យពីការយល់ដឹងនិងទទួល

---

[34] ម.ស.ម.ក "កម្រងជីវប្រវត្តិសកម្មជនដីធ្លី" http://bit.ly/21b6V96

ព័ត៌មានត្រឡប់ពីអ្នកចូលរួម ព្រមទាំងកែសម្រួលតាមព័ត៌មានត្រឡប់នោះមុននឹងចាប់ផ្ដើមចុះបេសកកម្មទៅតាមតំបន់គោលដៅ។

ដើម្បីឱ្យសេចក្ដីសន្និដ្ឋានរបស់យើងតំណាងឱ្យស្ត្រីដែលទទួលរងផលប៉ះពាល់ពីវិវាទដីធ្លីនៅទូទាំងប្រទេសកម្ពុជា យើងបានប្រើសមីការខាងក្រោមដើម្បីកំណត់ចំនួនស្ត្រីដែលយើងត្រូវធ្វើការស្ទង់មតិ៖

$$x = Z(^{c}/_{100})^2 r(100 - r)$$

$$n = {}^{Nx}/_{((N-1)E^2 + x)}$$

$$E = Sqrt[^{(N-n)x}/_{n(N-1)}$$

អិន (n) គឺជាចំនួនសំណាក អ៊ី (E) គឺជាចំនួនតូចនៃភាពលម្អៀង អិន (N) គឺជាចំនួនប្រជាជន អ័រ (r) គឺជាចំនួននៃការឆ្លើយតបដែលយើងចាប់អារម្មណ៍ទៅលើ និង ហ្សិត Z(c/100) គឺជាតម្លៃសំខាន់សម្រាប់កម្រិតទំនុកចិត្ត ស៊ី (c)។

យើងកំណត់ចំនួនតូចនៃភាពលម្អៀងដែលទទួលយកបានក្នុងអត្រា ៤% និងកម្រិតទំនុកចិត្តរបស់យើងក្នុងអត្រា ៩៥%។ អត្រានេះតំណាងឱ្យការជឿជាក់របស់យើងថាប្រសិនបើយើងធ្វើការស្ទង់មតិដូចគ្នាចំនួន ១០០ ដង លទ្ធផលចេញមកនឹងស្ថិតក្នុងចន្លោះអត្រា +/- ៤% នៃការស្ទង់មតិលើកដំបូងដែលយើងធ្វើចំនួន ៩៥ ដងក្នុងចំណោម ១០០ដង។ ដោយសាររបាយការណ៍នានាអះអាងថា យ៉ាងហោចណាស់មានប្រជាពលរដ្ឋចំនួន ៧០ ម៉ឺននាក់ទទួលរងផលប៉ះពាល់អវិជ្ជមានពីវិវាទដីធ្លីចាប់តាំងពីឆ្នាំ ២០០០ មកម្ល៉េះ[35] និងថា ស្ត្រីមានចំនួន ៥១% នៃប្រជាពលរដ្ឋខ្មែរសរុប[36] ដូច្នេះចំនួនស្ត្រីដែលប៉ាន់ស្មានថាពាក់ព័ន្ធក្នុងវិវាទដីធ្លីមានចំនួន ៣៥៧ ពាន់នាក់ ហើយនេះជាតួលេខប្រើប្រាស់សម្រាប់ការរាប់ "ចំនួនប្រជាពលរដ្ឋ" នៅក្នុងការស្ទង់មតិនេះ។ ដូច្នេះ ចំនួនសំណាកដែលស្មើទ្បើងរបស់យើងមានចំនួន ៦០០ នាក់។

ខណៈដែលស្ត្រីមួយចំនួនធំបានទទួលរងផលប៉ះពាល់ពីវិវាទដីធ្លីនៅកម្ពុជា បណ្ដាញទំនាក់ទំនងមិនគ្រប់គ្រាន់ ភាពខ្វះខាតនៃការមានទិន្នន័យដ៏ទូលំទូលាយអំពីសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារវិវាទដីធ្លីនិងកង្វះធនធានសុទ្ធតែជាមូលហេតុធ្វើឱ្យការកំណត់ពីអ្នកចូលរួមស្ទង់មតិជាសក្ខានុពលរបស់យើងត្រូវតែមានលក្ខណៈលម្អៀងមិនអាចជៀសបាន។ ដូច្នេះ យើងពឹងផ្អែកលើបណ្ដាញដែលមានពីមុនស្រាប់ដើម្បីកំណត់សហគមន៍ដែលសាកសមនឹងការស្ទង់មតិ។ វិធីសាស្ត្រនេះយោងទៅតាម "ការជ្រើសរើសសំណាកតាមបណ្ដាញ" ហើយទោះបីជាមានការកំណត់ពីវិសាលភាពនៃការស្ទង់មតិដែលយើងបានគិតពិចារណាថាអាចយកធ្វើជាតំណាងបាននោះក៏ដោយ ឱ្យតែការពឹងផ្អែកលើការផ្ដល់យោបល់ជ្រើសរើសអ្នកចូលរួមធ្វើឱ្យវិធីសាស្ត្រមាន

---

[35] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ យុទ្ធនាការផ្ដល់ប្លង់កម្មសិទ្ធិដីធ្លីធ្វើឱ្យមានការរំលោភបំពាន" (ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៣) http://bit.ly/1U5ECUL

[36] អង្គការមូលនិធិអាស៊ី "តួនាទីរបស់ស្ត្រីនៅកម្ពុជា" (ខែសីហា ឆ្នាំ ២០០៣) http://bit.ly/2aMXPfK

លក្ខណៈលម្អៀងស្រាប់ទៅហើយ ដូច្នេះដែនកំណត់ដូចបានលើកឡើងខាងលើនោះ បានបង្ហាញពីលទ្ធភាពដែលពុំអាចប្រើប្រាស់បច្ចេកទេសជ្រើសរើសសំណាកបែបវិទ្យាសាស្ត្រប្រសើរជាងនេះបានឡើយ។ ការប្រឹក្សាយោបល់ជាមួយនឹងតំណាងសហគមន៍ និង បណ្ដាញពាក់ព័ន្ធផ្សេងទៀតរបស់ ម.ស.ម.ក បានជួយយើងដើម្បីកំណត់យកសហគមន៍ចំនួន ២២ នៅក្នុងខេត្តចំនួន ១២ បន្ថែមពីលើរាជធានីភ្នំពេញ ដែលជាទីតាំងសាកសមសម្រាប់ការចុះបេសកកម្មនៅតាមតំបន់គោលដៅ។




ក្នុងអំឡុងពេលចុះបេសកកម្មចំនួន ៥ លើក ចាប់ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ ២០១៦ ម.ស.ម.ក បានសម្ភាសន៍ជាមួយស្ត្រីចំនួន ៦១២ នាក់មកពីក្រុមជាតិពន្ធចំនួន ៥ ក្រុម៖ ៧១,៧% ជាជនជាតិខ្មែរ ៥,១% ជាជនជាតិកួយ ២០,៥% ជាជនជាតិព្នង[37] ២,៥% ជាជនជាតិស្អៀង និង ០,២% ជាជនជាតិខ្មែរក្រោម។ អ្នកចូលរួមទាំងអស់ជាប់ពាក់ព័ន្ធក្នុងវិវាទដីធ្លីជាមួយរដ្ឋ ក្រុមហ៊ុនឯកជន ឬបុគ្គលមានអំណាច។ ស្ត្រីដែលបានចូលរួមសម្ភាសន៍មានអាយុចាប់ពី ១៥ ដល់ ៧១ ឆ្នាំ ប៉ុន្តែស្ត្រីភាគច្រើនមានអាយុចាប់ពី ៣១ ដល់ ៦០ ឆ្នាំ (៦៨,២%)។ ស្ត្រីភាគច្រើនមានគ្រួសាររួចហើយ (៧៦,១%) ស្ត្រីចំនួនស្ទើរតែមួយភាគប្រាំគឺជាស្ត្រីមេម៉ាយ (១៨,៥%) និងមានតែ ៣,១% ដែលនៅលីវ។ ស្ត្រីចំនួនជាងពាក់កណ្ដាល (៥២,៨%) មិនដែលបានចូល

[37] ដែលត្រូវបានគេស្គាល់ផងដែរថាជាព្នង

សាលារៀននោះទេ។ ស្ត្រីតែចំនួន ៤,២% ប៉ុណ្ណោះដែលរស់នៅម្នាក់ឯង ហើយករណីនេះឆ្លុះបញ្ចាំងពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍នៅក្នុងវប្បធម៌ខ្មែរ។

បន្ថែមពីលើស្ត្រីដែលចូលរួមស្ទង់មតិ ក្រុមការងារគម្រោងកម្មវិធីកំណែទម្រង់ដីធ្លីបានធ្វើការសម្ភាសន៍ផ្ទាល់ចំនួន ៣៧ដង នៅក្នុងសហគមន៍ចំនួន ១០ ក្នុងខេត្តចំនួន ៨ ដោយសមាជិកសហគមន៍ និងអ្នកតំណាងទាំងបុរស និងស្ត្រីទទួលបានព័ត៌មានទូទៅលម្អិតអំពីវិវាទដីធ្លីទាំងនេះ។

## ៣.៣ ទំហំទូលាយ និងដែនកំណត់

វិសាលភាពទូលាយនៃការស្ទង់មតិនេះ អាចឱ្យគម្រោងកម្មវិធីកំណែទម្រង់ដីធ្លីលើកឡើងពីលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួនថា តំណាងឱ្យស្ត្រីទាំងអស់ដែលទទួលរងផលប៉ះពាល់ ដោយសារវិវាទដីធ្លីនៅកម្ពុជា។ ទោះជាយ៉ាងណា តាមការប្រមូលទិន្នន័យនីមួយៗ វាមានដែនកំណត់ជាក់លាក់មួយចំនួនដែលរឹតត្បិតដល់លទ្ធផលនៃការស្រាវជ្រាវនេះ។

ដូចបានរៀបរាប់នៅក្នុងផ្នែកវិធីសាស្ត្រនៃរបាយការណ៍នេះ ក្រុមការងារគម្រោងកម្មវិធីកំណែទម្រង់ដីធ្លីបានប្រើ ៉ការជ្រើសរើសសំណាកតាមបណ្តាញ៉ នៅពេលកំណត់យកសហគមន៍គោលដៅ ដែលករណីនេះធ្វើឱ្យលទ្ធផលស្ទង់មិតមានកម្រិតលម្អៀង។ ទោះជាយ៉ាងណា ការប្រើវិធីសាស្ត្រជ្រើសរើសសំណាកនេះធ្វើឱ្យ ម.ស.ម.ក អាចសម្រេចបានទៅតាមការសន្យាក្នុងការតាមដានស្ថានភាពរបស់សហគមន៍ ដែលទទួលរងផលប៉ះពាល់ និងបន្តផ្តល់ការគាំទ្រតាមការចាំបាច់។

បន្ថែមលើនេះ លទ្ធផលពីការស្រាវជ្រាវនេះទំនងជាមានបញ្ហាបន្តិចបន្តួចដោយសារកម្រិតមិនឆ្លើយតបខ្លះៗ ដែលសម្របសម្រួលចំនួនសំណាកសម្រាប់សំណួរជាក់លាក់មួយចំនួនផងដែរ។ ទោះជាយ៉ាងណាក្តី ជាចុងក្រោយយើងជឿជាក់ថាការបង្ហាញភាពលម្អៀងនេះ ពុំមានផលប៉ះពាល់ខាងស្ថិតិទៅលើសេចក្តីសន្និដ្ឋាននៃរបកគំហើញពីការស្រាវជ្រាវនេះឡើយ។

# ៤. ឥទ្ធិពលនៃវិវាទនៅលើស្ត្រី

ផ្នែកនេះនឹងបង្ហាញពីរបកគំហើញនៃការស្រាវជ្រាវ ដែលនឹងបកស្រាយពីករណីដែលស្ត្រីទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារវិវាទដីធ្លីនៅកម្ពុជា។

## ៤.១ ការរំលោភបំពានសិទ្ធិលើដីធ្លី

### *៤.១.១ អសន្តិសុខនៃការកាន់កាប់ដីធ្លី*

ជាការគួរឱ្យបារម្ភ ការស្ទង់មតិរបស់យើងបានបង្ហាញឱ្យដឹងថាស្ត្រីដែលទទួលរងផលប៉ះពាល់ដោយសារវិវាទដីធ្លីចំនួនតែ ៦,៣% ប៉ុណ្ណោះអាចដឹងថាស្ថានភាពកាន់កាប់ដីធ្លីរបស់ពួកគាត់នាពេលបច្ចុប្បន្នមិនមានអ្វីចោទជាបញ្ហាទេ។ ស្ត្រីចំនួនច្រើនជាងពាក់កណ្ដាល (៥២,៤%) មានអារម្មណ៍ថាការកាន់កាប់ដីធ្លីរបស់ពួកគាត់ "គ្មានសុវត្ថិភាព" នោះទេ ហើយចំនួនច្រើនជាងមួយភាគបួន(២៦,៥%)បានរាយការណ៍ថាស្ថានភាពកាន់កាប់ដីធ្លីរបស់ពួកគាត់ "គ្មានសុវត្ថិភាពទាល់តែសោះ"។ ដោយហេតុថាសមត្ថភាពរបស់ស្ត្រីក្នុងការបំពេញតួនាទីតាមទំនៀមទម្លាប់ ដែលកំណត់ឱ្យតាមវប្បធម៌ខ្មែរ គឺពឹងផ្អែកលើសុវត្ថិភាពនៃការ កាន់កាប់ដីធ្លីនោះ អសុវត្ថិភាពនៃការកាន់កាប់ដីធ្លីរបស់ស្ត្រីដែលបណ្ដាលមកពីវិវាទដីធ្លី ទំនងជាមូលហេតុនៃក្ដីបារម្ភដ៏ធំរបស់ស្ត្រីទាំងនោះ។




បន្ថែមពីលើនេះ ស្ត្រីភាគច្រើន (៨០,៤%) បារម្ភថាពួកគាត់នឹងត្រូវបណ្ដេញចេញនាពេលអនាគតដោយសារតែគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការ (ស្ត្រីចំនួនតែ ២% ប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការ) និងការគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនឯកជនត្រូវបានកំណត់ថាជាមូលហេតុបឋមនៅ

ពីក្រោយកង្វះខាតសុវត្ថិភាពកាន់កាប់ដីធ្លីនេះ។ ប៉ុន្តែ សូម្បីតែអ្នកដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការហើយក្តីក៏មិនធានាពីសន្តិសុខនៃការកាន់កាប់ដីធ្លីដែរ ទោះបីតាមទ្រឹស្តីថាអ្នកមានប័ណ្ណកម្មសិទ្ធិដីធ្លីជាផ្លូវការអាចធានាលើសុខសុវត្ថិភាពកាន់កាប់ដីធ្លីក៏ដោយ នេះក៏ដោយសារតែការអនុវត្តច្បាប់នៅទន់ខ្សោយ។ នៅក្នុងភូមិគ្រួស ឃុំអន្លង់រុន ស្រុកថ្មគោល ខេត្តបាត់ដំបង គម្រោងកម្មវិធីកំណែទម្រង់ដីធ្លី បានរកឃើញថាអ្នកភូមិត្រូវបានបុគ្គលមានអំណាចរំលោភយកដីស្រែរបស់ពួកគាត់ ទោះបីជាពួកគាត់មានប័ណ្ណកម្មសិទ្ធិផ្លូវការលើដីដែលទទួលបានការការពារស្របច្បាប់ហើយក្តី។ ទោះបីជាសហគមន៍បានដាក់ពាក្យបណ្តឹងជាច្រើនទៅអាជ្ញាធរ និងតុលាការ ប៉ុន្តែពួកគាត់នៅមិនទាន់ទទួលបានដំណោះស្រាយណាមួយ អស់រយៈពេលជិត ២០ ឆ្នាំមកហើយបន្ទាប់មានហេតុការណ៍រំលោភយកដីនោះ។

### *៤.១.២ ការបណ្តេញចេញដោយបង្ខំ*

ការបណ្តេញចេញដោយបង្ខំ ដែលធ្វើឡើងប្រឆាំងនឹងឆន្ទៈរបស់អ្នកកាន់កាប់ដីដោយគ្មានការផ្តល់ ឬការទទួលបានទម្រង់ការការពារស្របតាមផ្លូវច្បាប់ ឬការការពារតាមវិធីសមស្របផ្សេងទៀត គឺជាការបង្កឱ្យមានការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។[38] តាមការស្ទង់មតិរបស់ ម.ស.ម.ក បានបង្ហាញឱ្យឃើញពីការរីករាលដាលនៃការបណ្តេញចេញដោយបង្ខំ និងមានលក្ខណៈជាប្រព័ន្ធនៅទូទាំងប្រទេសកម្ពុជាថា ស្ត្រីចំនួន ២៤,៤% ត្រូវបានបណ្តេញចេញពីផ្ទះរបស់ពួកគាត់ ហើយការបណ្តេញចេញស្ទើរតែទាំងអស់ (៩៨%) ធ្វើឡើងដោយការបង្ខំឬប្រើអំពើហិង្សា។ ដោយមានចំនួនកើនឡើងនៃហេតុការណ៍នៃការបណ្តេញចេញនេះចំនួន ៨៩,២% ដែលត្រូវបានបណ្តេញចេញ មិនទទួលបានការជូនដំណឹងជាមុនអំពីការបណ្តេញចេញនោះឡើយ ហើយចំនួន ៨៩,៩% មិនទទួលបានសំណងអ្វីនោះទេ។

របកគំហើញនៃការស្រាវជ្រាវទាំងនេះ បង្ហាញភស្តុតាងយ៉ាងច្បាស់ថាការបណ្តេញចេញដែលកើតមាននៅកម្ពុជាបំពាននឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ តាមរយៈការបំពានលើសិទ្ធិទទួលបានទីលំនៅសមរម្យ សិទ្ធិទទួលបានសុវត្ថិភាពនៃការកាន់កាប់ដីធ្លី សិទ្ធិទទួលបានសន្តិសុខបុគ្គល ការរួចផុតពីការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងសិទ្ធិជាច្រើនទៀតដែលទទួលស្គាល់ជាអន្តរជាតិថាជាស្តង់ដាសិទ្ធិមនុស្ស។[39]

---

[38] អនុសាសន៍ទូទៅលេខ ៧ ស្តីពីសិទ្ធិមានលំនៅឋានគ្រប់គ្រាន់ (កថាខណ្ឌ១ នៃមាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖ ការបណ្តេញចេញដោយបង្ខំ របស់គណៈកម្មាធិការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃអង្គការសហប្រជាជាតិ) ង/១៩៩៨/២២ (ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩៧) http://bit.ly/HbQDIV

[39] អនុសាសន៍ទូទៅលេខ ៧ ស្តីពីសិទ្ធិមានលំនៅឋានគ្រប់គ្រាន់ (កថាខណ្ឌ ១ នៃមាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(៖ ការបណ្តេញចេញដោយបង្ខំ របស់គណៈកម្មាធិការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃអង្គការសហប្រជាជាតិ) ង/១៩៩៨/២២ (ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩៧) http://bit.ly/HbQDIV

### ៤.១.៣ តំបន់តាំងលំនៅថ្មីមិនគ្រប់គ្រាន់

ក្នុងចំណោមស្ត្រីចំនួន ១៤៩នាក់ ដែលត្រូវបានបណ្តេញចេញពីផ្ទះរបស់ខ្លួន មានស្ត្រីចំនួន ៩០,៨% ទទួលបានការផ្លាស់ប្តូទីលំនៅថ្មីទៅរស់នៅក្នុងតំបន់ទីតាំងថ្មី។ ក៏ប៉ុន្តែក្រៅពីការផ្តល់លំនៅក្នុងតំបន់តាំងលំនៅថ្មី មានស្ត្រីជាច្រើននាក់នៅតែបន្តទទួលរងការរំលោភបំពានសិទ្ធិមនុស្សជាច្រើន។ ជាក់ស្តែង ការសម្ភាសន៍ជាច្រើន ដែលក្រុមការងារគម្រោងកម្មវិធីកំណែទម្រង់ដីធ្លី បានធ្វើជាមួយតំណាងសហគមន៍ ជាធម្មតាគឺកង្វល់ពីលក្ខខណ្ឌរស់នៅមិនល្អត្រូវបានរកឃើញនៅតាមតំបន់តាំងទីលំនៅថ្មីដែលផ្តល់ឱ្យដល់អ្នកមានវិវាទដីធ្លី។ ករណីនេះបានអះអាងនូវលទ្ធផលពីការស្រាវជ្រាវពីពេលមុនរបស់ ម.ស.ម.ក រកឃើញថាតំបន់តាំងលំនៅថ្មីជារឿយៗមានលក្ខណៈមិនទាន់គ្រប់គ្រាន់ជាច្រើន។[40]

ជាការគួរឱ្យព្រួយបារម្ភ ស្ត្រីចំនួន ៨៨,៣% ដែលរស់នៅក្នុងតំបន់តាំងលំនៅថ្មីបានរាយការណ៍ថា ពួកគាត់មិនមានអារម្មណ៍សុវត្ថិភាពនៅក្នុងលំនៅដ្ឋានសព្វថ្ងៃរបស់ពួកគាត់នោះទេ ដែលជាការរំលោភបំពានសិទ្ធិមនុស្សមូលដ្ឋានពីការរួចផុតពីការភ័យខ្លាច។ លើសពីនេះ ស្ត្រីច្រើនជាងពាក់កណ្តាល (៥២%) បានចង្អុលបង្ហាញថានៅក្នុងតំបន់តាំងលំនៅថ្មី ពួកគាត់មិនទទួលបានហេដ្ឋារចនាសម្ព័ន្ធដូចជា៖ សាលារៀន មន្ទីរពេទ្យ ឬមន្ទីរសម្រាកព្យាបាល ផ្សារ ផ្លូវថ្នល់ អគ្គិសនី ការផ្គត់ផ្គង់ទឹកស្អាត ឬប្រព័ន្ធលូដំណើរការនោះឡើយ។ បន្ថែមពីលើនេះ ស្ត្រីចំនួន ៩១.៤% ដែលកំពុងរស់នៅក្នុងតំបន់តាំងលំនៅថ្មីបានបង្ហាញឱ្យដឹងថាពួកគាត់មានក្តីបារម្ភថាពួកគាត់អាចនឹងត្រូវបានបណ្តេញចេញជាថ្មីម្តងទៀតនាពេលអនាគត ដែលប្រការនេះជាការបង្ហាញពី អសុវត្ថិភាពនៃការកាន់កាប់ដីធ្លីកម្រិតខ្ពស់ ។




[40] របាយការណ៍ស្តីពី "កម្ពុជា៖ ដីកំពុងមានទំនាស់ ព័ត៌មានទូទៅពីស្ថានភាពដីធ្លី" របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ជ.ម.ក) (ខែធ្នូ ឆ្នាំ ២០១៣) http://bit.ly/2aihu9a

## ៤.២ ការយាយី និងការគំរាមកំហែងពីសំណាក់អាជ្ញាធរ និងស្ថាប័នឯកជន

ស្ត្រីដែលធ្លាប់មានវិវាទដីធ្លីស្ទើរតែទាំងអស់តែងតែទទួលរងនូវការគំរាមកំហែង ការយាយី ការឃាត់ខ្លួន ឬអំពើហិង្សាពីសំណាក់អាជ្ញាធរ ឬក្រុមហ៊ុនសម្បទានដី រួមទាំងកម្លាំងសន្តិសុខឯកជន ឬបុគ្គលិកក្រុមហ៊ុន។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ទាំងអស់ មានអ្នកផ្តល់សម្ភាសន៍ចំនួន ៩៤,៥% ធ្លាប់ត្រូវបានគំរាមកំហែង ចំនួន ៧៣,១% ធ្លាប់ទទួលរងការយាយី ឬ គំរាមកំហែង ចំនួន ៣៣,៦% ធ្លាប់ជួបអំពើហិង្សា និងចំនួន ២,១% ធ្លាប់ត្រូវបានអាជ្ញាធរចាប់ខ្លួន។ តួលេខនេះត្រូវបានយកមកប្រៀបធៀបជាមួយនឹងស្ត្រីដែលធ្លាប់មានវិវាទដីធ្លីជាមួយនឹងក្រុមហ៊ុនសម្បទានដី៖ ស្ត្រីចំនួន ៥៩,៥% ធ្លាប់ត្រូវបានគំរាមកំហែង ចំនួន ៤៩% ធ្លាប់ត្រូវបានគេយាយី ចំនួន ២៤% ធ្លាប់ជួបអំពើហិង្សា និងចំនួន ១,៥% ធ្លាប់ត្រូវបានចាប់ខ្លួន។

**តើអ្នកធ្លាប់ត្រូវបានគំរាម យាយី ឬចាប់ខ្លួនដោយអាជ្ញាធរ និង/ឬ ក្រុមហ៊ុនឬទេ ***




*អ្នកផ្តល់សម្ភាសន៍អាចផ្តល់ចម្លើយលើសពីមួយ

## ៤.៣ អសុវត្ថិភាពផ្នែកសេដ្ឋកិច្ច

ជាការមិនគួរឱ្យភ្ញាក់ផ្អើលទេដែលថាជីវភាពរបស់ប្រជាពលរដ្ឋខ្មែរជាច្រើន នៅតែបន្តពឹងផ្អែកលើដីធ្លី (អ្នកផ្តល់សម្ភាសន៍ចំនួន ៨៥,៥% ធ្លាប់មានដីមុនពេលមានវិវាទដីធ្លី) ស្ត្រីភាគច្រើនបំផុត (ចំនួន ៩៨%) បានរាយការណ៍ថាវិវាទដីធ្លីបានប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ពួកគាត់ ដោយមានគ្រួសារចំនួន ៩១,៣% ធ្លាប់មានបទពិសោធន៍ពីការថយចុះប្រាក់ចំណូលគ្រួសាររបស់ពួកគាត់។ លទ្ធផលពីការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញឱ្យដឹងពីករណីមួយចំនួនដែលវិវាទដីធ្លីបង្កើនឱ្យមានអសុវត្ថិភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ផលលំបាកក្នុងការទិញ

ម្ហូបអាហារឱ្យបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ និងតម្រូវការថ្នាំសង្កូវ មិនត្រូវបានផ្តល់ឱ្យទាន់ពេលក្នុងករណីបន្ទាន់ និងបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចចម្បងៗដែលករណីទាំងនេះរំលោភបំពានសិទ្ធិទទួលបានម្ហូបអាហារ និងការថែទាំសុខភាព។

**តើមានការប្រែប្រួលស្ថានភាពហិរញ្ញវត្ថុដោយសារវិវាទដីធ្លីដែរឬទេ តើមានផលប៉ះពាល់ដូចខាងក្រោមនេះទេ?***




*អ្នកផ្តល់សម្ភាសន៍អាចផ្តល់ចម្លើយលើសពីមួយ

ចំពោះបញ្ហាសមាជិកគ្រួសារធ្វើចំណាកស្រុកទៅរកការងារនៅទីកន្លែងផ្សេងជារឿយៗ គឺជាបុរសដែលធ្វើចំណាកស្រុក ជាហេតុធ្វើឱ្យស្ត្រីមានបន្ទុកបន្ថែមត្រូវនៅផ្ទះមើលថែកូនក្នុងបន្ទុក និងទទួលរាប់រងការងារបន្ថែមនៅក្នុងគ្រួសារ។

បន្ថែមលើផលប៉ះពាល់រយៈពេលវែង ស្ត្រីចំនួនស្ទើរតែពាក់កណ្តាល (៤៤,៦%) បានរាយការណ៍ថាបានខ្ចីបំណុលពីធនាគារដើម្បីកាត់បន្ថយការលំបាកផ្នែកហិរញ្ញវត្ថុរបស់ពួកគាត់ ដែលបណ្តាលមកពីវិវាទដីធ្លី។ សហគមន៍បានសម្តែងភាពមិនសប្បាយចិត្តពីការខ្ចីបំណុលនៅពេលផ្តល់កិច្ចសម្ភាសន៍ ដោយហេតុថាភាគច្រើនមិនមានទំនុកចិត្តថាពួកគេអាចសងបំណុលរួចឡើយ។ ជាក់ស្តែងបញ្ហានេះបានកើតឡើងនៅពេលដែលគ្រួសារពឹងផ្អែកលើការខ្ចីបំណុលបន្ថែមដើម្បីធ្វើការទូទាត់សងបំណុលចាស់ ជាហេតុធ្វើឱ្យពួកគាត់ធ្លាក់ចូលក្នុងវដ្តនៃប្រាក់បំណុល។

## ៤.៤ ផលប៉ះពាល់លើទំនាក់ទំនងគ្រួសារ

មានស្ត្រីចំនួនច្រើនជាងពាក់កណ្តាលប៉ុណ្ណោះ (៥១,១%) បានអះអាងថាវិវាទដីធ្លីបានប៉ះពាល់ដល់ទំនាក់ទំនងគ្រួសាររបស់ពួកគាត់ ដែលនេះបង្ហាញថាផលវិបាកអវិជ្ជមានពីវិវាទដីធ្លីមានវិសាលភាពលើសពីវិបត្តិសេដ្ឋកិច្ចទៅទៀត។

## តើវិវាទដីធ្លីប៉ះពាល់ដល់ទំនាក់ទំនងគ្រួសារអ្នកឬទេ?




ស្ត្រីដែលបានជួបប្រទះនូវការធ្លាក់ចុះខាងទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹង ប្តី/សហព័ទ្ធ មានចំនួន ៤៤,១% ឬកូនៗ មានចំនួន ១៤,៤% ប៉ុន្តែស្ត្រីខ្លះក៏បានគិតថាទំនាក់ទំនងរបស់គាត់ជាមួយនឹងបងប្អូនមានចំនួន ២,៩% មានការធ្លាក់ចុះដោយសារតែវិវាទដីធ្លីផងដែរ។ មូលហេតុចម្បង ៤ យ៉ាងដែលធ្វើឱ្យទំនាក់ទំនងគ្រួសារធ្លាក់ចុះគឺទុក្ខព្រួយផ្លូវចិត្តដោយសារតែវិវាទដីធ្លីមានចំនួន ៤៥,២% ក្តីបារម្ភពីបញ្ហាហិរញ្ញវត្ថុ មានចំនួន ៣៣,៦% ការបាត់បង់ដីមានចំនួន ២៧,៦% និងសុខភាពមិនល្អ មានចំនួន ៧%។

### ៤.៥ អំពើហិង្សាក្នុងគ្រួសារ

លទ្ធផលពីការស្ទង់មតិរបស់ ម.ស.ម.ក អះអាងបន្ថែមពីការលើកឡើងថាវិវាទដីធ្លីនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារកើនឡើង ដែលស្ត្រីមានគ្រួសារចំនួន ២៣% ដែលមានវិវាទដីធ្លីកំណត់ដោយខ្លួនឯងថាជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ[41] និង ចំនួន ៥៣,៩% នៃស្ត្រីទាំងនេះមិនដែលជួបអំពើហិង្សាជាមួយនឹងដៃគូរបស់ពួកគាត់មុនពេលមានវិវាទដីធ្លីនោះទេ។ ជាការទទួលស្គាល់យ៉ាងទូលាយថាវិវាទទោះបីជាក្នុងកម្រិតទាបក្តីអាចបណ្តាលឱ្យមានអំពើហិង្សាទាក់ទងនឹងយែនឌ័រកើនឡើង ដូច្នេះខណៈដែលករណីនេះជាការបារម្ភមួយ គឺមិនគួរឱ្យភ្ញាក់ផ្អើលទេដែលស្ត្រីបានរាយការណ៍ពីការកើនឡើងនូវអំពើហិង្សាក្នុងគ្រួសារ បន្ទាប់ពីមានវិវាទដីធ្លីនោះ។ ទោះជាយ៉ាងណាក្តី ខណៈដែលកិច្ចពិភាក្សាតាមក្រុមរបស់ ម.ស.ម.ក និងការស្រាវជ្រាវពីពេលមុនបានអះអាងថាមូលហេតុចម្បងនៃការកើនឡើងអំពើហិង្សាក្នុងគ្រួសារ ដោយសារតែវិវាទដីធ្លីគឺបណ្តាលមកពីប្តី/ដៃគូជាបុរសបដិសេធប្រពន្ធរបស់ពួកគាត់ចំណាយពេលច្រើនធ្វើយុទ្ធនាការជាងធ្វើកិច្ចការងារផ្ទះ។ លទ្ធផលពីការ

[41] ដោយសារភាពរសើបនៃសំណួរនេះ អ្នកអាចសន្មតដោយទុកចិត្តបានថាចំនួនជាក់ស្តែងមានច្រើនជាងចំនួនដែលបានលើកឡើងមកនេះទៅទៀត។

ស្រាវជ្រាវរបស់យើងមានលក្ខណៈផ្ទុយពីការលើកឡើងនេះបន្តិចដោយសារយើងឃើញថា មានស្ត្រីតែមួយនាក់ប៉ុណ្ណោះដែលអះអាងថាអំពើហិង្សាពីប្តីរបស់នាង ដោយសារតែប្តីនោះមិនគាំទ្រសកម្មនិយមរបស់នាង។ ហើយស្ត្រីចំនួន ៩១% បានរាយការណ៍ថាប្តីរបស់ពួកគាត់គាំទ្រសកម្មនិយមទាមទារសិទ្ធិដីធ្លីរបស់ពួកគាត់។

**តើអំពើហិង្សាក្នុងគ្រួសារបានកើនឡើងបន្ទាប់ពីវិវាទដីធ្លីចាប់ផ្តើមដែរ ឬទេ?**




នៅក្នុងការស្វែងរកមូលហេតុចម្បងនៃការកើនឡើងអំពើហិង្សា ចម្លើយដូចគ្នាច្រើនបំផុតដែលស្ត្រី មានចំនួន ៤០,៦% ឆ្លើយតបទៅនឹងសំណួរពីមូលហេតុដែលពួកគាត់គិតថាប្តី ឬសហព័ទ្ធរបស់ពួកគាត់ប្រើអំពើហិង្សាលើពួកគាត់ គឺមូលហេតុទទួលទានគ្រឿងស្រវឹងហួសកម្រិត (ដែលកើនឡើងដល់ចំនួន ៦១,៦% ករណីពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារចាប់តាំងពីមានវិវាទដីធ្លីមក)។ មូលហេតុផ្សេងដែលកំណត់បាននោះ រួមមានភាពតានតឹងកើនឡើងបន្ទាប់ពីបាត់បង់ដីមានចំនួន ១៧,៩% ការឈ្លោះគ្នាជុំវិញរឿងបាត់បង់ចំណូលមានចំនួន ១៧,៩% ទុក្ខព្រួយផ្លូវចិត្តមានចំនួន ១១,៣% និងការមិនព្រមព្រៀងគ្នាជាទូទៅមានចំនួន ៦,៦%។ ប៉ុន្តែខណៈដែលករណីនេះហួសពីវិសាលភាពនៃរបាយការណ៍នេះ ក្នុងការសាកសួរអំពីហេតុផលដែលនាំឱ្យមានបញ្ហាទាំងនេះ និងវិធានការពីការការពារភាពស្របច្បាប់នឹងអំពើហិង្សានេះ ក៏ការស្រាវជ្រាវដែលមានពីមុនបានលើកឡើងថាស្ត្រីជាអ្នកទន់ខ្សោយជាងបុរស ហើយបុរសជាអ្នកត្រួតត្រាដែលគេអាចបកស្រាយបានថា គឺជាមូលហេតុនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារមិនចេះចប់មិនចេះហើយនៅក្នុងប្រទេសកម្ពុជា៖ ក្នុង ករណីនេះ ការទទួលទានគ្រឿងស្រវឹងហួសកម្រិតត្រូវបានមើលឃើញថាជាធាតុផ្សំបន្ថែមនៃអំពើហិង្សាជាជាងហាតុផលផ្សេង។

ស្ត្រីចំនួនមួយភាគបួន (២៥,៧%) តែប៉ុណ្ណោះដែលប្រាប់ឱ្យដឹងថាពួកគាត់ជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារនិងបានស្វែងរកជំនួយពីអាជ្ញាធរមូលដ្ឋានអន្តរាគមន៍លើអំពើហិង្សានោះ។ ជំនឿដែលមានយូរហើយដែលថាអំពើហិង្សាក្នុងគ្រួសារគឺជារឿងក្នុងគ្រួសារ និងហួសពីដែនសមត្ថកិច្ចរបស់ស្ថាប័នដែលនៅក្រៅរង្វង់គ្រួសារអាចមានឥទ្ធិពលដល់ការសម្រេចចិត្តរបស់ស្ត្រីខ្លះ ថានឹងមិនបន្តស្វែងយុត្តិធម៌ តាមរយៈបណ្តាញផ្លូវច្បាប់ឡើយ ដោយពួកគាត់គិតថាអាជ្ញាធរនឹងមិនចាត់ចំណាត់ការអ្វីនោះទេ។ ក៏ប៉ុន្តែជា ការគួរឱ្យកត់សម្គាល់ថាករណីចំនួន ៨១,៥% បានប្តឹងទៅអាជ្ញាធរ ហើយអាជ្ញាធរបានចាត់ចំណាត់ការលើជនជាប់ចោទ។

## ៤.៦ ផលប៉ះពាល់លើកុមារ

ជាការគួរឱ្យចាប់អារម្មណ៍ ការកើនឡើងនៃអំពើហិង្សាមិនត្រឹមតែត្រូវបានមើលឃើញរវាងប្តី និងប្រពន្ធនោះទេ ប៉ុន្តែក៏កើតឡើងរវាងម្តាយ និងកូនផងដែរដូចជា អ្នកម្តាយចំនួន ៤០,១% ដែលមានវិវាទដីធ្លីបានថ្លែងថាពួកគាត់ប្រើអំពើហិង្សាដាក់កូនៗរបស់ពួកគាត់ ក្នុងនោះចំនួនស្ទើរតែពាក់កណ្តាល (៤៨,១%) មិនបានប្រើអំពើហិង្សាលើកូនៗរបស់ពួកគាត់មុនពេលមានវិវាទដីធ្លីនោះទេ។ ករណីនេះពាក់ព័ន្ធជាមួយនឹងលទ្ធផលពីការស្រាវជ្រាវដែលស្ត្រីចំនួន ៨២,៦% បានរាយការណ៍ថាមានអារម្មណ៍ខឹងសម្បាបន្ទាប់ពីមានវិវាទដីធ្លី ដែលករណីនេះអាចជាកត្តាធ្វើឱ្យមានអំពើហិង្សាកើនឡើង។ ក្រៅពីមានអំពើហិង្សាកើនឡើងដាក់លើកូនៗរបស់ពួកគាត់ ស្ត្រីក៏បានកត់សម្គាល់នូវករណីផ្សេងៗទៀតមួយចំនួន ដែលពួកគាត់មានអារម្មណ៍ថាកូនៗរបស់ពួកគាត់ទទួលរងផលប៉ះពាល់អវិជ្ជមានពីវិវាទដីធ្លី ដែលករណីទាំងនេះជាប្រភពនៃក្តីបារម្ភរបស់ពួកគាត់។

**ប្រសិនបើមាន តើវិវាទដីធ្លីមានផលប៉ះពាល់ដល់កូនៗរបស់អ្នកដោយរបៀបណាខ្លះ?***




*អ្នកផ្តល់សម្ភាសន៍អាចផ្តល់ចម្លើយលើសពីមួយ

ផលប៉ះពាល់ខាងផ្នែកចិត្តសាស្ត្រពីវិវាទដីធ្លីលើកុមារហាក់ដូចជាកាន់តែច្បាស់ឡើងដោយសារស្ត្រីចំនួន ៤០,៩% បានរាយការណ៍ថាកូនៗរបស់ពួកគាត់ឆាប់ខឹង ឬងាយឃំ គឺដោយសារតែមូលហេតុនៃវិវាទដីធ្លី។ ផលប៉ះពាល់ចម្បងផ្សេងទៀតដែលកំណត់បានគឺការឱ្យកូនឈប់រៀនមានចំនួន ៤៣,៩% និងការឱ្យកូនទៅធ្វើការមានចំនួន ៣៦% ទំនងជាមកពីស្ថានភាពសេដ្ឋកិច្ចគ្រួសារធ្លាក់ចុះ។ នៅក្នុងករណីជាច្រើនការធ្វើបែបនេះបង្កើតឱ្យមានពលកម្មកុមារ ដែលកំណត់ដោយអង្គការពលកម្មអន្តរជាតិថា "*ការងារបានដកហូតភាពជាកុមារភាពរបស់កុមារ* រួមទាំងការងារដែល"*ប៉ះពាល់ដល់ការរៀនសូត្រដោយធ្វើឱ្យពួកគាត់បាត់ឱកាសទៅសាលារៀន*

*តម្រូវឱ្យពួកគាត់ឈប់រៀនទាំងវ័យក្មេង" ឬតម្រូវឱ្យពួកគាត់ព្យាយាមរួមបញ្ចូលការសិក្សានៅសាលាជាមួយនឹងការធ្វើការងារធ្ងន់ និងរយៈពេលយូរ*។[42] ជាឧទាហរណ៍ នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សមាជិកសហគមន៍ដែលមានដីត្រូវបានរំលោភយកដោយឧកញ៉ាលីយ៉ុងផាត់ដើម្បីធ្វើជាចម្ការអំពៅ បាននិយាយដោយបើកចំហអំពីការឱ្យកូនឈប់រៀនទាំងនៅវ័យក្មេងដោយសារតែមូលហេតុវិវាទដីធ្លី។ ដោយសារតែដីរបស់ពួកគាត់ត្រូវបានរំលោភយក ពួកគាត់គ្មានលទ្ធភាពរកចំណូលពីការធ្វើស្រែចំការ ដូច្នេះហើយពួកគាត់ពឹងផ្អែកលើកូនឱ្យរកចំណូលដើម្បីបន្តជីវិត។ ដូច្នេះ កុមារអាយុត្រឹម ១៣ ឆ្នាំ ត្រូវបានបង្ខំឱ្យបោះបង់ការសិក្សាក្នុងពេលសំខាន់នៃការអភិវឌ្ឍខ្លួន និងលើសពីនេះត្រូវធ្វើដំណើរឆ្ងាយពីផ្ទះមកកាន់រាជធានីភ្នំពេញដើម្បីស្វែងរកការងារធ្វើ ដោយហេតុថាវិវាទដីធ្លីបំផ្លាញសេដ្ឋកិច្ចរបស់ពួកគាត់។ សហគមន៍បានប្រាប់ឱ្យដឹងថាកុមារៗជាច្រើនកំពុងធ្វើការនៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់នៅឯរាជធានីភ្នំពេញ ដោយត្រូវធ្វើការ ១២ ម៉ោងក្នុងមួយថ្ងៃក្នុងលក្ខខណ្ឌមិនសមរម្យ ស្រដៀងគ្នានេះដែរ ក្នុង ឃុំជី ខ លើ ខេត្តកោះកុង កុមារអាយុត្រឹម ១០ ឆ្នាំ ត្រូវបង្ខំឱ្យបោះបង់ការសិក្សា និងបច្ចុប្បន្នកំពុងធ្វើការនៅចំការអំពៅឱ្យជនដែលរំលោភយកដី។ សមាជិកសហគមន៍បានប្រាប់ឱ្យដឹងថា នេះគឺជាការខ្មាសអៀនមួយ ប៉ុន្តែវាជាការចំបាច់ ដោយសារតែពួកគាត់គ្មានលទ្ធភាពរកចំណូលពីដីរបស់ពួកគាត់បានទៀតទេ។

លទ្ធផលពីការស្រាវជ្រាវដែលអះអាងចំនួនកុមារជាច្រើនត្រូវបានបង្ខំឱ្យបោះបង់ការសិក្សា ដោយសារតែមូលហេតុវិវាទដីធ្លី និងជំនួសមកវិញនូវពលកម្មកុមារ រំលោភបំពាននឹងអនុសញ្ញាស្តីពីសិទ្ធិកុមារនិងអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិស្តីពីអាយុអប្បបរមាចូលបម្រើការងារដែលដាក់ឱ្យអនុវត្តនូវអាយុចូលបម្រើការងារអប្បបរមានៅក្នុងប្រទេសកំពុងអភិវឌ្ឍចាប់ពីអាយុ ១៤ ឆ្នាំ[43] ដែលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងពីរខាងលើនេះ និងមានចែងក្នុងច្បាប់ជាតិ។

## ៤.៧ ផលប៉ះពាល់ផ្នែកចិត្តសាស្ត្រ

ការបាត់បង់ផ្ទះសម្បែង ឬការងារ ជារឿយៗត្រូវបានចាត់ទុកថាជាហេតុការណ៍ដ៏ស្មុគស្មាញបំផុតមួយដែលមនុស្សជាតិអាចទ្រាំទ្របានរួមមានភាពស្មុគស្មាញក្នុងវិវាទដីធ្លីជាទូទៅពាក់ព័ន្ធនឹងការបាត់បង់ទាំងផ្ទះ និងការងារ ដូច្នេះហើយបានដាក់សម្ពាធធ្ងន់ធ្ងរលើសុខភាពផ្លូវចិត្តរបស់អ្នកដែលទទួលរងផលប៉ះពាល់ ជាពិសេសលើតួនាទីរបស់ស្ត្រីភាគច្រើនក្នុងនាមជាអ្នកមើលថែគ្រួសារ។ លទ្ធផលពីការស្ទង់មតិនេះបង្ហាញឱ្យដឹងថាវិវាទដីធ្លីមានផលប៉ះពាល់ផ្នែកចិត្តសាស្ត្រគួរឱ្យតក់ស្លុតទៅលើស្ត្រីក្នុងនោះ ស្ត្រីចំនួន ៩៨,២% បានរាយការណ៍ថាសុខភាពផ្លូវចិត្តរបស់ពួកគាត់មានបញ្ហាដោយសារតែវិវាទដីធ្លី ស្ត្រីដែលមានសុខភាពទ្រុឌទ្រោមចំនួន ៤៦,២%

---

[42] ឯកសារ "តើពលកម្មកុមារគឺជាអ្វី" របស់អង្គការពលកម្មអន្តរជាតិ (ILO) http://bit.ly/1dZyCvJ

[43] អនុសញ្ញាស្តីពីអាយុអប្បបរមាចូលបម្រើការងាររបស់អង្គការពលកម្មអន្តរជាតិ (ILO) (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ១៩៧៦) http://bit.ly/1lNdlbG

ធ្លាប់គិតថាបញ្ចប់ជីវិតរបស់ខ្លួន និងស្ត្រីចំនួន ១៨,១% បានព្យាយាមធ្វើអត្តឃាត។ លើសពីនេះ ស្ត្រីចំនួន ៣៥% បានឆ្លើយតបថាពួកគាត់នៅតែមានគំនិតចង់ធ្វើអត្តឃាត។

## ចាប់តាំងពីមានវិវាទដីធ្លីកើតឡើង តើអ្នកធ្លាប់គិតថា លែងចង់រស់ដែរឬទេ ?




ក្រៅពីមានអារម្មណ៍ចង់ធ្វើអត្តឃាត ផលប៉ះពាល់ផ្សេងទៀតដែលស្ត្រីបានរាយការណ៍ថាដោយសារតែវិវាទដីធ្លី ពួកគាត់ធ្លាប់មានអារម្មណ៍ដូចជា៖ កើតទុក្ខមានចំនួន ៧០,២% ភ័យខ្លាចមានចំនួន ៨៥,៣% ខឹងសម្បាមានចំនួន ៨២,៥% គិតអ្វីមិនចេញមានចំនួន ៨៣,៥% គិតថាខ្លួនគ្មានតម្លៃមានចំនួន ៦១,៧% គិតថាគ្មានសង្ឃឹមពីអនាគតមានចំនួន ៨០,៨% ភ័យព្រួយ ឬញាប់ញ័រក្នុងខ្លួនមានចំនួន ៦០,៧% និងងាយយំ មានចំនួន ៧២,៩%។ សូចនាករទាំងនេះអះអាងពីទំនាក់ទំនងរឹងមាំរវាងវិវាទដីធ្លី និងសុខភាពផ្លូវចិត្ត ដែលបង្ហាញពីតម្រូវការបន្ទាន់ឱ្យមានការអន្តរាគមន៍។ ក្រៅពីតម្រូវការបន្ទាន់នេះ មានស្ត្រីចំនួនតែ ១៦,៩% ប៉ុណ្ណោះដែលរាយការណ៍ថាមានបញ្ហាសុខភាពផ្លូវចិត្តដោយសារតែវិវាទដីធ្លី បានទទួលការប្រឹក្សាយោបល់ (ភាគច្រើនគឺពីអង្គការមិនមែនរដ្ឋាភិបាល រួមទាំងសមាគមអាដហុក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ អង្គការសេមធម៌កម្ពុជា អង្គការលីកាដូ និងកម្មវិធីសុខភាពផ្លូវចិត្ត)។ ក៏ប៉ុន្តែស្ត្រីស្ទើរតែទាំងអស់(៩៩%) ដែលបានរាយការណ៍ថាមានបញ្ហាសុខភាពផ្លូវចិត្តបានលើកឡើងថាពួកគាត់មានបំណងចង់ទទួលបានការប្រឹក្សាយោបល់នៅពេលអនាគត។ ក្នុងករណីមានទំនាក់ទំនងគ្នានេះអង្គការមិនមែនរដ្ឋាភិបាលគួរតែផ្តោតក្នុងគម្រោងនាពេលអនាគតរបស់ខ្លួនលើការលើកកម្ពស់ការគាំទ្រសុខភាពផ្លូវចិត្តដល់ស្ត្រីដែលទទួលរងផលប៉ះពាល់ពីវិវាទដីធ្លី។

# ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

លទ្ធផលពីការស្រាវជ្រាវនៅក្នុងរបាយការណ៍នេះអះអាងជាថ្មីថា ស្ត្រីរងផលប៉ះពាល់ដោយសារវិវាទដីធ្លីនៅកម្ពុជាក្នុងលក្ខខណ្ឌពិសេសមួយ និងបង្ហាញអំពីផលប៉ះពាល់គួរឱ្យមានក្តីកង្វល់ ដែលទាមទារឱ្យមានបទអន្តរាគមន៍ជាបន្ទាន់។ ដោយឡែក ការស្រាវជ្រាវរបស់យើងកត់សម្គាល់នូវក្តីកង្វល់ជាខ្លាំងចំនួន ៣ គឺ៖ ការរីករាលដាលកាន់តែច្រើនឡើងនៃអំពើហិង្សាក្នុងគ្រួសារដោយសារវិវាទដីធ្លី ភាពអន់ថយនៃសុខភាពផ្លូវចិត្តរបស់ស្ត្រីដោយសារតែវិវាទដីធ្លី និងផលប៉ះពាល់សំខាន់ៗលើកុមារ ដែលវិវាទដីធ្លីបង្កើនឱ្យមានអំពើហិង្សាក្នុងគ្រួសារកាត់បន្ថយការទទួលបានសិទ្ធិអប់រំនិងបង្កើនឱ្យមានពលកម្មកុមារ។ ផលប៉ះពាល់ទាំងនេះមានសក្តានុភាពរយៈពេលវែងឆ្ងាយនិងមានឥទ្ធិពលភ្លាមៗផងដែរ ដោយឡែកផលប៉ះពាល់ដល់កុមារគឺអាចគំរាមកំហែង ដល់ការអភិវឌ្ឍអនាគតរបស់ពួកគេ។ លទ្ធផលពីការស្រាវជ្រាវទាំងនេះផ្តល់នូវទិន្នន័យតាមបែបគុណភាពសំខាន់ក្នុងការគាំទ្រទៅការស្រាវជ្រាវនៅក្នុងវិស័យនេះ។

ខណៈដែលលទ្ធផលពីការស្រាវជ្រាវគាំទ្រយ៉ាងច្រើនដល់ការស្រាវជ្រាវពីមុន ប៉ុន្តែផ្ទុយនឹងការអះអាងពីពេលមុនដែលថាប្តីភាគច្រើនមិនគាំទ្រសកម្មនិយមទាមទារសិទ្ធិលើដីធ្លីរបស់ប្រពន្ធពួកគាត់ ជាក់ស្តែងលទ្ធផលពីការស្រាវជ្រាវរបស់យើងអះអាងថាភាពផ្ទុយគ្នានេះគឺជាការពិត ដោយស្ត្រីភាគច្រើនអះអាងថាប្តីរបស់ពួកគាត់គាំទ្រសកម្មនិយមរបស់ពួកគាត់ទៅវិញ។

ជាចុងក្រោយ លទ្ធផលពីការស្រាវជ្រាវរំលេចពីតម្រូវការបន្ទាន់របស់ស្ត្រីក្នុងការទទួលបានសុវត្ថិភាពកាន់កាប់ដីធ្លីប្រសើរជាងនេះនៅកម្ពុជា។ ក្នុងករណីនេះ ម.ស.ម.ក រំលឹកឡើងវិញ និងជម្រុញឱ្យរាជរដ្ឋាភិបាលកម្ពុជាអនុវត្តតាមអនុសាសន៍ទាំងអស់ដែលផ្តល់ជូននៅក្នុងរបាយការណ៍ឆ្នាំ ២០១៣ របស់យើងស្តីពី "*កម្ពុជា៖ ដីមានជម្លោះ*" ដែលពាក់ព័ន្ធនឹងតម្លាភាព សុវត្ថិភាពនៃការកាន់កាប់ដីធ្លី ការពិគ្រោះយោបល់ ការបណ្តេញចេញដោយបង្ខំ ការទទួលបានដំណោះស្រាយមានប្រសិទ្ធភាព និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពខាងសមាគម និងសេរីភាពចូលរួមប្រជុំ។[44] យោងតាមអនុសាសន៍ពីមុនដែលលើកឡើងពាក់ព័ន្ធនឹងការពិគ្រោះយោបល់និងការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម តាមលទ្ធផលពីការស្រាវជ្រាវក្នុងរបាយការណ៍នេះ សូមស្នើឱ្យមានការរួមបញ្ចូលនូវការវាយតម្លៃហេតុផលប៉ះពាល់យែនឌ័រ និងសិទ្ធិកុមារ។

លើសពីនេះ ម.ស.ម.ក ផ្តល់ជាអនុសាសន៍ខាងក្រោមដល់ភាគីពាក់ព័ន្ធ ដោយផ្អែកលើការស្រាវជ្រាវដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ ៖

[44] ទំព័រទី ៤០ ដល់ ៤២ នៃរបាយការណ៍ស្តីពី "កម្ពុជា៖ ដីកំពុងមានទំនាស់ ព័ត៌មានទូទៅពីស្ថានភាពដីធ្លី" របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក) (ខែធ្នូ ឆ្នាំ ២០១៣) http://bit.ly/1KtPNVy

## ៥.១ អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

### ៥.១.១ បញ្ហាអំពើហិង្សាក្នុងគ្រួសារ

រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ រួមទាំងក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងព័ត៌មានគួរតែ ៖

- ផ្សព្វផ្សាយព័ត៌មានពីច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដើម្បីបង្កើនការយល់ដឹងដល់សាធារណជន
- បង្កើនការអប់រំនៅតាមសាលារៀននិងសហគមន៍អំពីសារៈសំខាន់នៃសមភាពយេនឌ័រនិងថារាល់ទម្រង់ នៃអំពើហិង្សាក្នុងគ្រួសារ ដែលប្រព្រឹត្តដោយបុរស ឬស្ត្រី មិនអាចទទួលយកបាននោះទេ
- ធានាថារាល់ពាក្យបណ្តឹងទាំងអស់អំពីអំពើហិង្សាក្នុងគ្រួសារត្រូវបានអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ និងធានាថាស្ត្រីគ្រប់រូបទទួលបាននូវការការពារទាំងអស់ និង
- ផ្តល់វគ្គបណ្តុះបណ្តាលដល់អាជ្ញាធរមូលដ្ឋានអំពីរបៀបទទួលស្គាល់អំពើហិង្សាក្នុងគ្រួសារ និងរបៀប គាំទ្រជនរងគ្រោះឱ្យបានគ្រប់គ្រាន់។

### ៥.១.២ បញ្ហាសុខភាពផ្លូវចិត្ត

រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ រួមទាំងក្រសួងសុខាភិបាល គួរតែលើកកម្ពស់សេវាសុខភាពផ្លូវ ចិត្តតាមរយៈ ៖

- ការបណ្តុះបណ្តាលអ្នកចិត្តសាស្ត្រ គ្រូពេទ្យជំនាញ និង សិស្សនិស្សិតជំនាញខាងសុខភាពផ្លូវចិត្តឱ្យ បានច្រើន
- ការបង្កើតមន្ទីរសំរាកព្យាបាលផ្នែកសុខភាពផ្លូវចិត្តនៅទូទាំងប្រទេស និង
- ការផ្សព្វផ្សាយព័ត៌មាននៅតាមតំបន់គោលដៅដែលមានវិវាទដីធ្លីស្តីពីគ្រោះថ្នាក់នៃសុខភាពផ្លូវចិត្ត ទន់ខ្សោយ និងវិធីសាស្ត្រព្យាបាលជម្ងឺសុខភាពផ្លូវចិត្ត

### ៥.១.៣ បញ្ហាកុមារ

រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ រួមទាំងក្រសួងអប់រំ យុវជន និងកីឡា គួរតែ

- បែងចែងមូលនិធិ និងផ្តល់ការបណ្តុះបណ្តាលដល់អធិការការងារដើម្បីអនុវត្តច្បាប់ប្រឆាំងនឹងពលកម្ម កុមារ ព្រមទាំងបង្កើនការខិតខំប្រឹងប្រែងដើម្បីលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរទាំងអស់នៃពលកម្មកុមារ ដោយអនុលោមតាមមាត្រា ៦ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារដែលកម្ពុជាជារដ្ឋភាគី
- ធ្វើការជាមួយក្រុមហ៊ុនឯកជន និងវិនិយោគិនបរទេស ក្នុងការបង្កើនការយល់ដឹងពីភាពរាលដាលជា ទូទៅ និងផលប៉ះពាល់នៃពលកម្មកុមារ និង
- បណ្តុះបណ្តាលអ្នកជំនាញចិត្តសាស្ត្រ និងគ្រូពេទ្យជំនាញសុខភាពផ្លូវចិត្តកុមារ និងធានាពីលទ្ធភាព ទទួលបានដល់គ្រួសារដែលទើបនឹងពាក់ព័ន្ធនឹងវិវាទដីធ្លីនាពេលថ្មីៗនេះ និង

- អនុវត្តមាត្រា ៦៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យកុមារទទួលបានការសិក្សាយ៉ាងតិចណាស់ ៩ ឆ្នាំ។

## ៥.២ អនុសាសន៍សម្រាប់រដ្ឋសភា

- តាមដានការត្រួតពិនិត្យរបស់រដ្ឋាភិបាលលើច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ធ្វើវិសោធនកម្មលើច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដើម្បីធានា ឱ្យអនុលោមទៅតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងទោសប្បញ្ញត្តិជាក់លាក់។

## ៥.៣ អនុសាសន៍សម្រាប់ក្រុមហ៊ុន

- ប្រកាន់ខ្ជាប់នូវច្បាប់ជាតិ និងអន្តរជាតិនៅគ្រប់ប្រតិបត្តិការទាំងអស់
- ប្តេជ្ញាអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស ដែលការពារសិទ្ធិស្ត្រី និងសិទ្ធិកុមារ ព្រមទាំងដើរឱ្យស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងគោលការណ៍ស្តីអំពីសិទ្ធិកុមារនិងធុរកិច្ច[45] និងធានាផ្តល់ការបណ្តុះបណ្តាលអំពីគោលការណ៍សិទ្ធិមនុស្សដល់បុគ្គលិកទាំងអស់
- ជៀសវាងការបង្ក ឬរួមចំណែកឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិមនុស្សនៅក្នុងប្រតិបត្តិការរបស់ខ្លួនតាមរយៈការពិគ្រោះយោបល់សំខាន់ៗជាមួយនឹងអង្គការសង្គមស៊ីវិលមូលដ្ឋាននិងសហគមន៍ដែលរងការប៉ះពាល់ ជាពិសេសស្ត្រី នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃគម្រោងដែលបានស្នើឡើង និង
- ចេញមុខ និងផ្តល់ដំណោះស្រាយលើផលប៉ះពាល់អវិជ្ជមាន លើបញ្ហាសិទ្ធិមនុស្សនៅពេលកើតឡើងតាមរយៈការបង្កើតយន្តការដំណោះបណ្តឹងតវ៉ាពីលក្ខខណ្ឌការងារនៅគ្រប់កម្រិតប្រតិបត្តិការ។

## ៥.៤ អនុសាសន៍សម្រាប់ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល

- បង្កើនការយល់ដឹងដល់សហគមន៍អំពីសិទ្ធិស្ត្រី ជាពិសេសពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ តាមរយៈការអប់រំ និងការបណ្តុះបណ្តាល
- ផ្តល់ការគាំទ្រដល់សហគមន៍ដែលរងផលប៉ះពាល់ ដើម្បីធានាថាកូនៗរបស់ពួកគាត់ អាចនៅបន្តការរៀនសូត្របាន និងមិនឈប់រៀនដើម្បីទៅធ្វើការនោះទេ
- ឆ្លើយតបទៅនឹងតម្រូវការឱ្យមានការគាំទ្រសុខភាពផ្លូវចិត្តឱ្យបានច្រើនក្នុងចំណោមស្ត្រី ដែលពាក់ព័ន្ធនៅក្នុងវិវាទដីធ្លី តាមរយៈការផ្តល់មូលនិធិនិងអនុវត្តកម្មវិធីដែលផ្តោតសំខាន់លើការផ្តល់សេវាសុខភាពផ្លូវចិត្តដល់ស្ត្រី តាមដែលអាចធ្វើទៅបាននិង

---

[45] បន្ថែមពីលើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស អង្គការសង្គ្រោះកុមារ អង្គការអង្គការសហប្រជាជាតិបង្រួបបង្រួមសកលនិង អង្គការសហប្រជាជាតិមូនិធិកុមារ បានសហការគ្នាជំរុញការអភិវឌ្ឍសិទ្ធិកុមារ និងគោលការធុរកិច្ចដែលបានចេញផ្សាយនៅឆ្នាំ ២០១២ ដោយផ្តល់ធុរកិច្ចនូវគំនិតច្បាស់លាស់មួយពីទីកន្លែង និងរបៀបដែលធុរកិច្ចរបស់ពួកគាត់អាច ប៉ះពាល់ដល់កុមារ។ លោកអ្នកអាចរកមើលបានតាមរយៈ http://uni.cf/2b04zr0

- ឆ្លើយតបទៅនឹងតម្រូវការឱ្យមានសុវត្ថិភាពកាន់កាប់ដីធ្លីដល់ស្ត្រីតាមរយៈការផ្តល់មូលនិធិ និងអនុវត្តកម្មវិធីដែលផ្តោតលើការលើកកម្ពស់សុវត្ថិភាពកាន់កាប់ដីធ្លី។

# ឯកសារយោង

## ច្បាប់ ក្រឹត្យ បទបញ្ជា និងសេចក្តីសម្រេចរបស់កម្ពុជា

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០១១) http://bit.ly/29QGGid

សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ១៩៩៣ បានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៦), http://bit.ly/1hcJqYV

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៥) http://bit.ly/29WYurw

ច្បាប់ភូមិបាល នស/រកម/០៨០១/១៤ (ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០១)

## ច្បាប់ និងអនុសញ្ញាអន្តរជាតិ

### *សន្ធិសញ្ញា និងសេចក្តីប្រកាសអន្តរជាតិ*

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៧៩) http://bit.ly/1jkI3IM

អនុសញ្ញាស្តីពីអាយុអប្បបរមាចូលបម្រើការងាររបស់អង្គការពលកម្មអន្តរជាតិ(ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៧៦) http://bit.ly/1lNdIbG

អនុសញ្ញាស្តីពីសិទ្ធិកុមារ (ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ១៩៨៩) http://bit.ly/1fGCcXV

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦) http://bit.ly/1eeGc40

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២២០០ក (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមានថ្ងៃទី ៣ ខែមករា ឆ្នាំ ១៩៧៦) http://bit.ly/15WUwtO

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ២១៧ក III ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៤៨) http://bit.ly/1O8f0nS

### *លិខិតុបករណ៍អន្តរជាតិផ្សេងទៀត*

ការអធិប្បាយទូទៅលេខ ៧ ស្តីពីសិទ្ធិមានទីលំនៅគ្រប់គ្រាន់ (កថាខណ្ឌ ១ នៃមាត្រា ១១) នៃកតិកាសញ្ញាអន្តរ

ជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៖ ការបោះពុម្ពចេញដោយបង្គំ )ង/១៩៩៨/២២ (ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩៧) ផ្នែកទី ៣ http://bit.ly/HbQDIV

គណៈកម្មធិការអង្គកាសហប្រជាជាតិស្តីពីសិទ្ធិ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ សេចក្តីអត្ថាធិបាយទូទៅ លេខ ៧៖ សិទ្ធិទទួលបានទីលំនៅគ្រប់គ្រាន់ (កថាខណ្ឌ១ នៃមាត្រា១១)៖ ការបោះពុម្ពចេញដោយបង្គំ E/1998/22 (ថ្ងៃទី២០ ខែឧសភា ឆ្នាម១៩៩៧) http://bit.ly/HbQDIV

ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ របស់អង្គការសហប្រជាជាតិ (ឆ្នាំ ២០០០) http://bit.ly/16qXf1z

## *របាយការណ៍ និងឯកសារបោះពុម្ព*

ម. ស.ម.ក របាយការណ៍ស្តីពី "កម្ពុជា៖ ដីមានជម្លោះទិដ្ឋភាពស្ថានភាពដីធ្លី" (ខែធ្នូ ឆ្នាំ ២០១៣)
http://bit.ly/1KtPNVy

ម. ស.ម.ក ឯកសារស្តីពី "កម្រងជីវប្រវត្តិរបស់សកម្មជនដីធ្លី" http://bit.ly/29V2Cu7

អង្គការវិទ្យាស្ថានខ្មែរសំរាប់ប្រតិបត្តិការនិងសន្តិភាព ឯកសារ "សន្តិសុខមនុស្សជាតិ និងសិទ្ធិលើដីធ្លីនៅកម្ពុជា" (ឆ្នាំ ២០១៤) http://bit.ly/1VUGJ0B

អង្គការលីកាដូ ""ប្រពន្ធល្អ"៖ ស្ត្រីធ្វើយុទ្ធនាការទាមទារដី និងផលប៉ះពាល់នៃសកម្មនិយមសិទ្ធិមនុស្ស"(ឆ្នាំ ២០១៣) http://bit.ly/1MuL4FA

អង្គការស្ត្រីខ្មែរ របាយការណ៍អំពីផលប៉ះពាល់ខាងផ្នែកចិត្តសាស្ត្រនិងសង្គមសាស្ត្រពីការបណ្តេញចេញពីដីធ្លីដែលមានលើស្ត្រីនៅកម្ពុជាមានចំណងជើងថា"ពួកគេយកដីរបស់ខ្ញុំពួកគេយកជីវិតរបស់ខ្ញុំ"(ខែកុម្ភៈ ឆ្នាំ២០១៣)
http://bit.ly/1Y1BXwK

យូ.អេស.អេ.អាយ.ឌី (USAID)ឯកសារសង្ខេបស្តីពីការកាន់កាប់ដីធ្លី សិទ្ធិលើទ្រព្យសម្បត្តិ និងយែនឌ័រ៖ បញ្ហាប្រឈមនិងអភិក្រមដើម្បីពង្រឹងការកាន់កាប់ដីធ្លីនិងសិទ្ធិលើទ្រព្យសម្បត្តិរបស់ស្ត្រី(ខែកក្កដាឆ្នាំ២០១៣)
http://bit.ly/29qAwbN

## អត្ថបទសារព័ត៌មាន និងសេចក្តីប្រកាសព័ត៌មាន

អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ យុទ្ធនាការផ្តល់ប្លង់កម្មសិទ្ធិដីធ្លីធ្វើឱ្យមានការរំលោភបំពាន" (ថ្ងៃទី ១២ខែ មិថុនាឆ្នាំ២០១)http://bit.ly/17FLZsD

លោក ខេលីគ្រាស (Kelly Grace) និង អេង សុជី របស់សារព័ត៌មានខេមបូឌាដេលី "ច្បាប់ស្រី" នៅក្នុងសាលារៀនខ្មែរ(ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៥) http://bit.ly/1MPseWY

សូនៀខូលបាចង់រ(Sonia Kohlbacher)"ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដែលមានភាពចម្រូងចម្រាសស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋាភិបាល"សារព័ត៌មានខេមបូឌាដេលី(ថ្ងៃទី២៧ខែសីហាឆ្នាំ២០១៦)
http://bit.ly/2bsRWrm